កាកបាទក្រហមកម្ពុជា
CAMBODIAN RED CROSS




# របាយការណ៍សកម្មភាពការងារ ឆ្នាំ ២០១៦
# និង
# ផែនការសកម្មភាពការងារ ឆ្នាំ ២០១៧





# អារម្ភកថា



ឆ្នាំ២០១៦ ជាឆ្នាំទី៦ ដែលកាកបាទក្រហមកម្ពុជា បាននិងកំពុងបន្តអនុវត្ត យុទ្ធសាស្ត្រ ២០១១-២០២០ ដែលមានទស្សនវិស័យ រួមចំណែកពន្លឿនការកាត់បន្ថយភាពក្រីក្រ ការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការពារតម្លៃមនុស្សធម៌របស់ជនងាយរងគ្រោះ។ ក្នុងបេសកកម្ម ជាសមាគមជាតិនាំមុខគេ ក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជា បានប្រមូលផ្តុំកម្លាំងមនុស្សធម៌ ខិតខំសម្រេចឲ្យបាននូវទិសយុទ្ធសាស្ត្រទាំង ៤ គឺ៖

i. រួមចំណែកសង្គ្រោះជីវិតកសាងភាពធន់មាំទៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ
ii. រួមចំណែកកាត់បន្ថយអត្រាឈឺ និងស្លាប់នៃមាតា និងកុមារ ការពារជំងឺឆ្លង និងអន្តរាគមន៍សុខភាពគ្រាអាសន្ន
iii. លើកកម្ពស់គោលការណ៍គ្រឹះ តម្លៃមនុស្សធម៌ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងវប្បធម៌អហិង្សា
iv. ពង្រឹងការរក្សាកិត្តិនាម កាកបាទក្រហមកម្ពុជា ជាសមាគមជាតិមានដំណើរការល្អ

ក្នុងឆ្នាំ២០១៦ គ្រួសារងាយរងគ្រោះបំផុតចំនួន **១៣៣,៦៤២គ្រួសារ** បានទទួលដោយផ្ទាល់នូវអំណោយមនុស្សធម៌ ជាស្បៀងអាហារពីកាកបាទក្រហមកម្ពុជា ដោយឡែកប្រជាពលរដ្ឋនៅតាមជនបទរាប់ពាន់គ្រួសារទៀត បានទទួលផលពីការផ្តល់អណ្តូងទឹកស្អាត ស្រះទឹក និងការអប់រំសុខភាព ការលើកកម្ពស់សុខមាលភាពសង្គម ដែលប្រៀបធៀបជាមួយឆ្នាំ២០១៥ អ្នកទទួលផលសរុបមានការកើនឡើងប្រមាណជិត ២០០%។

ក្នុងស្ថានភាព ដែលព្រះរាជាណាចក្រកម្ពុជា រងផលប៉ះពាល់ដោយបញ្ហាប្រឈមជាសកល មានដូចជា បម្រែបម្រួលអាកាសធាតុ ការកើនកំដៅនៃភពផែនដី ការកើតជំងឺឆ្លងថ្មី ការកើតមានវិបត្តិផ្សេងៗ រួមជាមួយបញ្ហាសង្គមធំៗមួយចំនួនទៀតដូចជា៖ គ្រោះថ្នាក់ចរាចរណ៍ គ្រឿងញៀន គ្រឿងស្រវឹង អំពើហិង្សាក្នុងគ្រួសារ ចំណាកស្រុក។ល។ និង ។ល។ កាកបាទក្រហមកម្ពុជា បានយកចិត្តទុកដាក់បង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធថែមទៀត ជាមួយរាជរដ្ឋាភិបាល ពិសេសក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ក្នុងការអនុវត្តការងារនៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋាន សំដៅធ្វើយ៉ាងណាឱ្យសេវា និងការសម្របសម្រួលជួយសង្គ្រោះជនរងគ្រោះ និងងាយរងគ្រោះបំផុតនៅទូទាំងប្រទេស បានប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ដោយដើរទន្ទឹមជាមួយនឹងការបន្តពង្រឹងការធ្វើសវនកម្មផ្ទៃក្រៅ រួមមានសវនកម្មលើគណនីសរុប សវនកម្មគម្រោង/កម្មវិធីជាមួយដៃគូនីមួយៗ ហើយកំពុងជំរុញការធ្វើសវនកម្មផ្ទៃក្នុង នៅតាមសាខានីមួយៗ លើកកម្ពស់អភិបាលកិច្ចល្អ ការគ្រប់គ្រងមានតម្លាភាព និងគណនេយ្យភាព។

ក្នុងការបន្តបេសកកម្មមនុស្សធម៌ដ៏ឧត្តុង្គឧត្តម ខ្ញុំម្ចាស់ និងសហការីនៅកាកបាទក្រហមកម្ពុជា សូមទូលថ្វាយនូវព្រះមហាករុណាទិគុណយ៉ាងជ្រាលជ្រៅបំផុត ថ្វាយចំពោះ**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា និងសូមប្តេជ្ញាចិត្តបន្តដង្ហែតាមព្រះរាជគំរូវីរភាពរបស់ព្រះអង្គទាំងទ្វេ និងខិតខំទ្វេដងថែមទៀត បណ្តុះឧត្តមគតិមនុស្សធម៌ឲ្យកាន់តែទូលំទូលាយ បំផុសឲ្យមានការចូលរួមកាន់តែសកម្ម និងខ្លាំងក្លាថែមទៀត ដើម្បីសម្រេចបានបេសកកម្មមនុស្សធម៌ ដ៏ឧត្តុង្គឧត្តម។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលគាំទ្រដល់កាកបាទក្រហមកម្ពុជា និងមានវត្តមានជាអធិបតីដ៏ខ្ពង់ខ្ពស់ នៃការប្រារព្ធទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា រៀងរាល់ឆ្នាំ ញ៉ាំងឱ្យការរកមូលនិធិរបស់កាកបាទក្រហមកម្ពុជា សម្រេចបានជោគជ័យធំធេងជាបន្តបន្ទាប់។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួម ជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មពីស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ ក្រសួង ស្ថាប័ន មន្ទីរពាក់ព័ន្ធ ដៃគូសហប្រតិបត្តិការជាតិ អន្តរជាតិ វិស័យឯកជន និងសប្បុរសជនក្នុង និងក្រៅប្រទេសគ្រប់មជ្ឈដ្ឋាន សមាជិក សមាជិកា យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ដែលបង្កើតបានជាកម្លាំងសាមគ្គីភាពទូលំទូលាយ កម្លាំងមនុស្សធម៌រឹងមាំ ជួយធ្វើឱ្យកាកបាទក្រហមកម្ពុជា អាចសម្រេចបានបេសកកម្មលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋបានល្អប្រសើរជាលំដាប់។

លើសពីនេះទៅទៀត ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សម្តេច ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា នឹងបន្តជួយគាំទ្រដល់កាកបាទក្រហមកម្ពុជា ប្រកបដោយទឹកចិត្តសទ្ធាជ្រះថ្លា និងស្មោះស្ម័គ្រ ដើម្បីបុព្វហេតុមនុស្សធម៌ និងការពារបានសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៧*

***ប្រធាន***

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន***

# មាតិកា


**ផ្នែកទី១ ៖ របាយការណ៍សកម្មភាពការងារឆ្នាំ ២០១៦**.......១

**សេចក្តីផ្តើម**.......១

I. **និសយុទ្ធសាស្ត្រទី១ ៖ រួមចំណែកសង្គ្រោះជីវិតកសាងភាពធន់នៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ**.......២

***វិស័យស្នូលទី១៖ ការគ្រប់គ្រងគ្រោះមហន្តរាយ***.......២

សកម្មភាពទី១៖ ការផ្តល់អំណោយមនុស្សធម៌ដល់ជនរងគ្រោះ.......២

សកម្មភាពទី២៖ការកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ.......៣

១. ដោយមូលនិធិវើលម៉េត និងកាកបាទក្រហមកម្ពុជា.......៣

១.១. គម្រោងទឹកស្អាតនិងអនាម័យ.......៣

១.២. គម្រោងប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់.......៤

២. ប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់ នៃកម្មវិធីសុវត្ថិភាពសហគមន៍.......៤

៣. កម្មវិធីការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍.......៤

៤. គម្រោងសមាហរណកម្ម ការគ្រប់គ្រងគ្រោះមហន្តរាយ សុខភាព និងការអភិវឌ្ឍន៍ស្ថាប័ន.......៦

៥. គម្រោងកសាងភាពធន់នៅទីប្រជុំជន.......៦

៦. គម្រោងយុវជនកាកបាទក្រហមកម្ពុជា និងសុវត្ថិភាពចរាចរណ៍.......៧

II. **និសយុទ្ធសាស្ត្រទី២ ៖ រួមចំណែកកាត់បន្ថយអត្រាឈឺ និងស្លាប់ នៃមាតា និងកុមារ ការពារជំងឺឆ្លង និងអន្តរាគមន៍សុខភាពគ្រាអាសន្ន**.......៨

***វិស័យស្នូលទី២៖ សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍***.......៨

សកម្មភាពទី១៖ ការងារឥស្សរជនផ្តើមថ្នាក់ជាតិ.......៨

សកម្មភាពទី២៖ ការលើកកម្ពស់សុខភាពមាតា ទារក និងកុមារ.......១០

១. គម្រោងអភិវឌ្ឍន៍សុខភាពសហគមន៍មូលដ្ឋាន ឧបត្ថម្ភដោយកាកបាទក្រហមដាណឺម៉ាក.......១០

២. គម្រោងអភិវឌ្ឍន៍សុខភាពសហគមន៍មូលដ្ឋាន ឧបត្ថម្ភដោយកាកបាទក្រហមហ្វាំងឡង់.......១១

៣. គម្រោងអភិវឌ្ឍន៍សុខភាពសហគមន៍មូលដ្ឋាន ឧបត្ថម្ភដោយកាកបាទក្រហមអូស្ត្រាលី.......១២

៤. គម្រោងបង្កើននិរន្តរភាព នៃការប្រើប្រាស់ទឹកស្អាត និងអនុវត្តអនាម័យ.......១៣

៥. គម្រោងវិជ្ជាសង្គ្រោះបឋម ឧបត្ថម្ភដោយកាកបាទក្រហមកម្ពុជា កាកបាទក្រហមជប៉ុន និងកាកបាទក្រហមដាណឺម៉ាក.......១៤

III. **និសយុទ្ធសាស្ត្រទី៣ ៖ លើកកម្ពស់គោលការណ៍គ្រឹះ តម្លៃមនុស្សធម៌ សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ និងវប្បធម៌អហិង្សា**.......១៥

*វិស័យស្នូលទី៣៖ ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា* ........................ ១៥
សកម្មភាពទី១៖ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០១៦ ................ ១៥
សកម្មភាពទី២៖ ការលើកកម្ពស់ការផ្សព្វផ្សាយ អំពីចលនា គោលការណ៍គ្រឹះ និងច្បាប់ ................ ១៦
សកម្មភាពទី៣៖ គម្រោងស្តារទំនាក់ទំនងគ្រួសារ និងបញ្ជូនសារ ........................................ ១៨
សកម្មភាពទី៤៖ កម្មវិធីសុវត្ថិភាពសហគមន៍ ........................................................... ១៨
សកម្មភាពទី៥៖ ការផ្តល់ជំនួយសុខុមាលភាពសង្គម ....................................................... ១៩
IV. **ទិសយុទ្ធសាស្ត្រទី៤ ÷ ពង្រឹងការកេរ្តិ៍ឈ្មោះកាកបាទក្រហមកម្ពុជា ជាសមាគមជាតិមានដំណើរការល្អ**.២១
*វិស័យស្នូលទី៤៖ ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន* ................................................ ២១
សកម្មភាពទី១៖ ការអភិបាល និងការគ្រប់គ្រង ......................................................... ២១
សកម្មភាពទី២៖ ការអភិវឌ្ឍន៍សាខា អនុសាខា ......................................................... ២២
សកម្មភាពទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស ........................................ ២៣
៣.១. ការងារបុគ្គលិក ............................................................................... ២៣
៣.២. ការងារយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ............................................ ២៣
សកម្មភាពទី៤៖ ការអភិវឌ្ឍន៍ធនធានហិរញ្ញវត្ថុ ....................................................... ២៥
សកម្មភាពទី៥៖ ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ............................ ២៥
សកម្មភាពទី៦៖ ការអភិវឌ្ឍការងាររដ្ឋបាល ហិរញ្ញកិច្ច................................................ ២៦
សកម្មភាពទី៧៖ ការកសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និង របាយការណ៍ ........................ ២៦
**ផ្នែកទី២ ÷ ផែនការសកម្មភាពការងារ សម្រាប់ឆ្នាំ ២០១៧** ................................................ ២៧
*វិស័យស្នូលទី១ - ការគ្រប់គ្រងគ្រោះមហន្តរាយ* ......................................................... ២៧
*វិស័យស្នូលទី២ -សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍*.......................................... ២៧
*វិស័យស្នូលទី៣ -លើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌*...................................... ២៧
*វិស័យស្នូលទី៤ -ការអភិវឌ្ឍន៍ស្ថាប័ន និងការអភិវឌ្ឍន៍ធនធាន* ......................................... ២៨
សកម្មភាពទី១៖ ការអភិបាល និងការគ្រប់គ្រង ......................................................... ២៨
សកម្មភាពទី២៖ ការងារអភិវឌ្ឍន៍សាខា អនុសាខា ..................................................... ២៨
សកម្មភាពទី៣៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស.............................................. ២៩
សកម្មភាពទី៤៖ ការអភិវឌ្ឍន៍ធនធានហិរញ្ញវត្ថុ ....................................................... ២៩
សកម្មភាពទី៥៖ ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ............................ ២៩
សកម្មភាពទី៦៖ ការអភិវឌ្ឍការងាររដ្ឋបាល ហិរញ្ញកិច្ច................................................ ២៩
សកម្មភាពទី៧៖ ការកសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និង របាយការណ៍ ........................ ២៩
**សេចក្តីសន្និដ្ឋាន** .................................................................................... ៣០

# របាយការណ៍សកម្មភាពការងារ ឆ្នាំ ២០១៦
# និង
# ផែនការសកម្មភាពការងារ ឆ្នាំ ២០១៧

## ផ្នែកទី១ ÷ របាយការណ៍សកម្មភាពការងារ ឆ្នាំ ២០១៦

### សេចក្តីផ្តើម

ឆ្នាំ២០១៦ ជាឆ្នាំដែលគ្រោះមហន្តរាយដោយធម្មជាតិនៅកម្ពុជាមិនបានបង្ហាញរូបរាងធំដុំ លេចធ្លោ ដូចនៅបណ្តាប្រទេសក្នុងភូមិភាគ និងលើសកលលោកទេ ក៏ប៉ុន្តែបានកើតឡើងជាបន្តបន្ទាប់ ឥតឈប់ឈរជាពិសេសគ្រោះរាំងស្ងួតកាលពីដើមឆ្នាំនេះ បណ្តាលឲ្យប្រជាពលរដ្ឋខ្វះសូម្បីតែទឹកផឹក និងទឹកប្រើប្រាស់ ប៉ះពាល់ដល់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើន។ ទន្ទឹមនឹងនេះ គ្រោះមហន្តរាយបង្កឡើងដោយមនុស្សដូចជាគ្រោះថ្នាក់ចរាចរណ៍ គ្រោះអគ្គិភ័យ ជាដើម។ល។ នៅតែកើតឡើងជាបន្តបន្ទាប់រៀងរាល់ថ្ងៃឥតឈប់ឈរ។

កាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាប្រធាន បានជំរុញគ្រប់សកម្មភាពការងារ នៃវិស័យស្នូលទាំង៤ ឱ្យប្រតិបត្តិទៅដោយរលូន និងមានប្រសិទ្ធភាពដោយបានឆ្លើយតបចំពោះភាពងាយរងគ្រោះ និងរងគ្រោះសរុបចំនួន **១៣៣,៦៤២គ្រួសារ** ក្នុងនោះពីថ្នាក់កណ្តាលចំនួន **៥៣,៩៩៨គ្រួសារ** ពីថ្នាក់សាខាចំនួន **៧៩,៦៤៤គ្រួសារ** ច្រើនជាងឆ្នាំ២០១៥ចំនួន **៦៣,៩៣១គ្រួសារ**។ ស្របជាមួយការឆ្លើយតបដ៏មមាញឹកនេះ កាកបាទក្រហមកម្ពុជាបានពង្រឹងការរៀបចំព្រឹត្តិការណ៍សំខាន់ៗ ដទៃទៀត ដូចជាទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា និងអនុវត្តការងារផ្សេងៗ ទៅតាមផែនការ និងកម្មវិធីដែលបានគ្រោងទុក សម្រេចបានលទ្ធផលដូចខាងក្រោម ៖



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន ពេលចុះចែកអំណោយចំនួន ២,៦៥០គ្រួសារ នៅស្រុកពញាក្រែក និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ*

## I. ទិសយុទ្ធសាស្ត្រទី១ ÷ *រួមចំណែកសង្គ្រោះជីវិតកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ*

### វិស័យស្នូលទី១ ៖ ការគ្រប់គ្រងគ្រោះមហន្តរាយ

ឆ្នាំ២០១៦ ជាឆ្នាំដែលវិស័យស្នូលទី១ "**ការគ្រប់គ្រងគ្រោះមហន្តរាយ**" ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់សាខាទាំង២៥ រាជធានី ខេត្ត បានពង្រីកវិសាលភាពក្នុងការងារឆ្លើយតប ក៏ដូចជាការត្រៀមបង្ការធំធេងជាងមុន។ ពោលគឺ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងកសាងសហគមន៍ឱ្យមានភាពធន់ ទៅនឹងគ្រោះមហន្តរាយ ស្របតាមទិសយុទ្ធសាស្ត្រទី១។ ឆ្នាំនេះកាកបាទក្រហមកម្ពុជា សម្រេចបានលទ្ធផលដូចតទៅ៖

#### *សកម្មភាពទី១ ៖ ការផ្តល់អំណោយមនុស្សធម៌ ជូនជនរងគ្រោះ និងងាយរងគ្រោះ*

កាកបាទក្រហមកម្ពុជា បានផ្តល់អំណោយមនុស្សធម៌ ជូនប្រជាពលរដ្ឋងាយរងគ្រោះ និងរងគ្រោះដោយគ្រោះមហន្តរាយសរុបចំនួន **១២៤,៥២០គ្រួសារ** ក្នុងនោះចំនួន **៥៣,១០១គ្រួសារ** ទទួលពីថ្នាក់កណ្តាល និងចំនួន **៧១,៤១៩គ្រួសារ** ទទួលពីថ្នាក់សាខា។ អ្នកទទួលផលពីការឆ្លើយតបនីមួយៗ រួមមាន៖

- ប្រជាពលរដ្ឋក្រីក្រ ចាស់ជរាគ្មានទីពឹង ស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការ បុគ្គលិក កម្មករទាំង២៥រាជធានី ខេត្តសរុបចំនួន **៨៨,៤០១គ្រួសារ** ក្នុងនោះថ្នាក់កណ្តាលចំនួន ៤៩,៥១៦គ្រួសារ និងថ្នាក់សាខា ចំនួន ៣៨,៨៨៥គ្រួសារ។
- ប្រជាពលរដ្ឋរងគ្រោះដោយសារខ្យល់កន្ត្រាក់នៅ ២៥រាជធានី ខេត្តចំនួន **១០,៣០៦គ្រួសារ** ក្នុងនោះទទួលអំណោយពីថ្នាក់កណ្តាលចំនួន ៩៥៤គ្រួសារ និងពីសាខាចំនួន ៩,៣៥២គ្រួសារ (មានមនុស្សស្លាប់៥៥នាក់ និងរបួស១០៦នាក់)។
- ប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះរាំងស្ងួត នៅ១៧ខេត្តចំនួន **២២,០០០គ្រួសារ** បានទទួលទឹកសម្រាប់ផឹក និងប្រើប្រាស់ ក្នុងនោះពីថ្នាក់កណ្តាល ៦១០គ្រួសារ និងពីសាខា ២១,៣៩០គ្រួសារ។





*លោកជំទាវអគ្គលេខាធិការ កក្រក និងឯ.ឧ. ប្រធានគណៈកម្មាធិការ ព្រមទាំងនាយិកាសាខា កំពុងចាត់ចែងចែកទឹកនៅខេត្តកំពង់ស្ពឺ*

- ប្រជាពលរដ្ឋរងគ្រោះដោយសារជំនន់ទឹកភ្លៀងនៅ ៣រាជធានី ខេត្តចំនួន **២,៣៨៨គ្រួសារ** ក្នុងនោះអំណោយពីថ្នាក់កណ្តាល ១,៨៩០គ្រួសារ និងពីសាខា ៤៩៨គ្រួសារ។
- ប្រជាពលរដ្ឋរងគ្រោះដោយសារមីននៅ ៨ខេត្ត ចំនួន **២៣គ្រួសារ** ក្នុងនោះអំណោយពីថ្នាក់កណ្តាល ១គ្រួសារ និងពីសាខា ចំនួន ២២គ្រួសារ (មានមនុស្សស្លាប់៦នាក់ និងរបួស១៧នាក់)។

- ប្រជាពលរដ្ឋរងគ្រោះដោយសារអគ្គិភ័យនៅ ២៥រាជធានី ខេត្តចំនួន **៦ ៦២គ្រួសារ** ក្នុងនោះអំណោយពីថ្នាក់កណ្តាល ៦៥គ្រួសារ និងពីសាខាចំនួន ៥៩៧គ្រួសារ (មានមនុស្សស្លាប់២នាក់ និងរបួស២នាក់)។
- ប្រជាពលរដ្ឋរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន **៧៤០ករណី** ស្លាប់ចំនួន **៦១នាក់** និងរបួសចំនួន **៦៧៩នាក់** ក្នុងនោះអំណោយពីថ្នាក់កណ្តាល ៦៥នាក់ និងពីសាខា ៦៧៥នាក់។
- អំណោយថ្នាក់កណ្តាល ជូនអនុសាខាកាកបាទក្រហមកម្ពុជាទាំង១២ ក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំនេះចំនួន ៣ដង រួមមានអង្ករ**៣៩៦តោន** មីយើង**៧,២០០កេស** ត្រីខ**៧,២០០កំប៉ុង** មុង**៧,២០០** ភួយ**៧,២០០** សារុង**៧,២០០** និងក្រមា**៧,២០០** ដែលគិតជាថវិកា**២៩៩,៤០០ដុល្លារ** សម្រាប់ចែកជូនប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះ។

### *សកម្មភាពទី២ ៖ ការកសាងសហគមន៍ឲ្យមានភាពធន់ទៅនឹងគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ មានការងារចំនួន ៦រួមមាន ៖*

- **ដោយមូលនិធិជីលម៉េត និងកាកបាទក្រហមកម្ពុជាថ្នាក់**កណ្តាល បាននិងកំពុងអនុវត្តគម្រោង២គឺ ៖
  - ✓ **គម្រោងទឹកស្អាត និងអនាម័យ** បានផ្តល់អណ្តូងទឹកចំនួន **១៦៨** ស្រះទឹកចំនួន **១៨** និងស៊ីទែនទឹកចំនួន **៧** សម្រាប់អ្នកទទួលផល**១០,២៤៥គ្រួសារ** នៅខេត្តចំនួន ១២ ដែលប្រឈមនឹងកង្វះទឹកស្អាតសម្រាប់បរិភោគ និងប្រើប្រាស់ រួមមានខេត្តព្រះវិហារ (អណ្តូង៥៥) បាត់ដំបង(ស្រះទឹក៤) ឧត្តរមានជ័យ (ស្រះទឹក១៣) ស្ទឹងត្រែង(អណ្តូង៤០) តាកែវ(ស្រះ១ និងផ្លូវចូលទៅស្រះទឹក២ខ្សែ) ក្រចេះ(អណ្តូង២០) ពោធិ៍សាត់(អណ្តូង១៦) កំពង់ឆ្នាំង(អណ្តូង៣ និងស៊ីទែនទឹកចំណុះ២០ម៉ែត្រគូប៥) កំពត(អណ្តូង១) បន្ទាយមានជ័យ(អណ្តូង២០) កំពង់ស្ពឺ(អណ្តូង១ ស៊ីទែនទឹក២) និងមណ្ឌលគិរី (អណ្តូងស្នប់១២)។









*លោកជំទាវអគ្គលេខាធិការ និង អគ្គលេខាធិការរងទី១ កក្រក ប្រគល់អណ្តូងទឹកស្អាត និង ផ្ទះ នៅខេត្តបន្ទាយមានជ័យ និងខេត្តកំពត*

✓ **គម្រោងប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់** បាននិងកំពុងអនុវត្តនៅខេត្តកណ្តាល ក្នុងស្រុកលើកដែក ឃុំចំនួន២ ភូមិចំនួន៣ និងប្រជាពលរដ្ឋចំនួន **២២៣គ្រួសារ** មានជីវភាពប្រសើររួចហើយ និងចំនួន**២៤៦គ្រួសារ** ទៀតកំពុងទទួលផលពីសេវាកម្មប្រាក់កម្ចីសរុប **៣០,០០០ដុល្លារ**។





*ប្រជាពលរដ្ឋនៅស្រុកលើកដែកកំពុងមានជីវភាពប្រសើរឡើង ពីអាជីវកម្មរបស់គ្រួសារ តាមរយៈគម្រោងប្រាក់កម្ចី*

- **ប្រាក់កម្ចីខ្នាតតូចពុំមានការប្រាក់ នៃកម្មវិធីសុវត្ថិភាពសហគមន៍** បាននិងកំពុងអនុវត្តនៅខេត្តចំនួន៤ គឺខេត្តពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ បានផ្តល់ប្រាក់កម្ចីពុំមានការប្រាក់ចំនួន**២៩,៤០០ដុល្លារ** ជូនគ្រួសាររងគ្រោះដោយសារមីន និងគ្រួសារក្រីក្រខ្វះលទ្ធភាពចំនួន **១៤៧គ្រួសារ** ក្នុង១គ្រួសារ ទទួលបានចំនួន **២០០ដុល្លារ** ដើម្បីប្រកបរបរចិញ្ចឹមជីវិត។







*ប្រជាពលរដ្ឋក្នុងស្រុកគោលដៅ កំពុងទទួលផល ពីមុខរបរតម្បាញ ចញ្ចឹមសត្វ និងដំណាំអនុផល*

- **កម្មវិធីកាត់បន្ថយហានិភ័យសហគមន៍** ឧបត្ថម្ភដោយកាកបាទក្រហមហ្វាំងឡង់ បាននិងកំពុងអនុវត្តនៅ៣ខេត្ត គឺខេត្តកំពង់ធំ កំពង់ចាម និងកំពង់ឆ្នាំង ស្រុកចំនួន៣ ឃុំចំនួន៥ ភូមិចំនួន១៨ អនុវត្តដោយយុវជនចំនួន ៥២នាក់ និងអ្នកស្ម័គ្រចិត្តចំនួន ៤៦នាក់ មានអ្នកទទួលផលសរុបចំនួន **៤,៤៨០គ្រួសារ** ដែលបានចូលរួមកសាងភាពធន់ របស់សហគមន៍ឲ្យមានសមត្ថភាព ត្រៀមបង្ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយផ្សេងៗ និងបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍។ លទ្ធផលសម្រេចបាន រួមមាន ៖

✓ ផ្តល់ម៉ាស៊ីនបូមទឹកចំនួន **២៣គ្រឿង** សម្រាប់សហគមន៍បូមទឹក ក្នុងវិស័យកសិកម្ម។

✓ ផ្តល់ធុងចម្រោះចំនួន **១៧០ធុង** សម្រាប់គ្រួសារក្រីក្រនៅក្នុងសហគមន៍។

✓ ផ្តល់ឧបករណ៍ពង្រោះស្រូវចំនួន **២៨គ្រឿង** សម្រាប់សហគមន៍ពង្រោះស្រូវ។

✓ ផ្តល់កាណូតចំនួន **២គ្រឿង** សម្រាប់សហគមន៍ប្រើប្រាស់សង្គ្រោះនៅពេលមានទឹកជំនន់។



*តំណាងម្ចាស់អំណោយ កក្រ ហ្វាំងឡង់ ក្នុងពិធីផ្តល់កាណូតសម្រាប់ប្រើប្រាស់ក្នុងសហគមន៍ពេលទឹកជំនន់ នៅខេត្តកំពង់ឆ្នាំង*

- ✓ ផ្តល់ម៉េក្រូចំនួន **១គ្រឿង** សម្រាប់សហគមន៍ផ្សព្វផ្សាយ ដើម្បីសង្គ្រោះនៅពេលមានទឹកជំនន់។
- ✓ ផ្តល់អាវយឺត មួកចំនួន ៣០០ កាបូបដាក់សម្ភារៈចំនួន **៧៨** និងបំពាក់សម្ភារៈក្លឹបយុវជនចំនួន ៥ សាលាសម្រាប់សហគមន៍ប្រើប្រាស់។
- ✓ ចុះធ្វើប៉ាន់ប្រមាណសមត្ថភាពសហគមន៍ចំនួន **១៩ភូមិ** និង៥សាលាគោលដៅ មានអ្នកចូលរួមចំនួន **៨៥២នាក់** (ស្ត្រី ៤០៤នាក់)។



*អ្នកស្ម័គ្រចិត្តកំពុងពន្យល់អំពីការកសាងផែនការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍ និង ក្រុមការងារចុះវាយតម្លៃបញ្ចប់ការអនុវត្តគម្រោងនៅខេត្តកំពង់ធំ*

- ✓ ផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពមូលដ្ឋាន អំពីគោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ វិជ្ជាសង្គ្រោះបឋម និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ជូនមន្ត្រីសាខា អនុសាខា ក្រុមយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១៦៨នាក់** ដើម្បីបង្កើនចំណេះដឹង ជំនាញ និងសមត្ថភាពចូលរួមជួយអប់រំផ្សព្វផ្សាយបន្ត។



*មន្ត្រីផ្តល់វគ្គបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុជូនអ្នកស្ម័គ្រចិត្ត នៃសាខា កក្រក ខេត្តកំពង់ឆ្នាំង*

✓ បានផ្តល់អណ្តូងទឹកស្អាត ដោយបំពាក់ប្រព័ន្ធបូមសូឡា ជូនសហគន៍ចំនួន ២ នៅសហគមន៍គោលដៅ នៃខេត្តកំពង់ឆ្នាំង។




*សកម្មភាពខួងអណ្តូងទឹកស្អាតនៅខេត្តកំពង់ឆ្នាំង និងម្ចាស់អំណោយចុះពិនិត្យប្រព័ន្ធបូមទឹកសូឡានៅខេត្តកំពង់ធំ*

- **គម្រោងសមាហរណកម្ម ការគ្រប់គ្រងគ្រោះមហន្តរាយ សុខភាព និងការអភិវឌ្ឍន៍ស្ថាប័ន** ឧបត្ថម្ភដោយ កាកបាទក្រហមចិន បាននិងកំពុងអនុវត្តនៅខេត្តកំពង់ស្ពឺ ក្នុងស្រុកឧត្តុង្គ ឃុំចំនួន២ ភូមិចំនួន៥ អនុវត្តដោយអ្នកស្ម័គ្រចិត្តចំនួន **២០នាក់** និងមានអ្នកទទួលផលសរុបចំនួន **៧៩៦គ្រួសារ**។ លទ្ធផលសម្រេចបាន រួមមាន ៖




*មន្ត្រីគម្រោងកំពុងពន្យល់អំពីអនាម័យ ទឹកស្អាតជូនសហគមន៍ និង អ្នកស្ម័គ្រចិត្តកំពុងគូសផែនទីភាពងាយរងគ្រោះ*

  ✓ ផ្តល់សម្ភារៈមួយចំនួន រួមមាន ម៉ូតូហុងដាស៊េរីឆ្នាំ២០១៦ចំនួន១គ្រឿង កុំព្យូទ័រ១គ្រឿង ព្រីនធ័រ១គ្រឿង តុការិយាល័យ៣ និងកៅអី៥ សម្រាប់ការប្រើប្រាស់ក្នុងដំណើរការអនុវត្តគម្រោង។

  ✓ ផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាព អំពីអនាម័យទឹកស្អាត គោលការណ៍គ្រឹះរបស់ចលនា វិជ្ជាសង្គ្រោះបឋម ការគ្រប់គ្រងគ្រោះមហន្តរាយ បម្រែបម្រួលអាកាសធាតុ ការប៉ាន់ប្រមាណភាពងាយរងគ្រោះ ជូនអ្នកស្ម័គ្រចិត្តចំនួន **២០នាក់** ដើម្បីជួយផ្សព្វផ្សាយបន្តនៅតាមសហគមន៍គោលដៅ។

- **គម្រោងកសាងភាពធន់នៅទីប្រជុំជន** ឧបត្ថម្ភដោយកាកបាទក្រហមហ្វាំងឡង់ បាននិងកំពុងអនុវត្តនៅខេត្តបន្ទាយមានជ័យ ក្នុងក្រុងសិរីសោភ័ណ សង្កាត់ចំនួន២ ភូមិចំនួន៦ វិទ្យាល័យចំនួន៣ អនុវត្តដោយយុវជនចំនួន **២៧នាក់** និងអ្នកស្ម័គ្រចិត្តចំនួន **៣៣នាក់** មានអ្នកទទួលផលសរុបចំនួន **៣,០៤១គ្រួសារ**។ លទ្ធផលសម្រេចបាន រួមមាន ៖

✓ ផ្ដល់វគ្គបណ្ដុះបណ្ដាលសមត្ថភាព អំពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការប៉ាន់ប្រមាណភាពងាយរងគ្រោះ ជូនអ្នកស្ម័គ្រចិត្តចំនួន **២៩នាក់** ដើម្បីជួយផ្សព្វផ្សាយបន្តនៅតាមសហគមន៍គោលដៅ។

✓ ផ្ដល់សម្ភារៈសង្គ្រោះបឋម ជូនអ្នកស្ម័គ្រចិត្តចំនួន **៣៣កញ្ចប់** និងវិទ្យាល័យចំនួន **១២កញ្ចប់**។



មន្ត្រីគម្រោង និងយុវជន កក្រក កំពុងពិភាក្សាអំពីហានិភ័យក្នុងសាលារៀន នៅក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

- **គម្រោងយុវជនកាកបាទក្រហមកម្ពុជា និងសុវត្ថិភាពចរាចរណ៍** ឧបត្ថម្ភដោយកាកបាទក្រហមអូស្ត្រាលីអង្គការសម្ព័ន្ធអន្តរជាតិដើម្បីទប់ស្កាត់ផលប៉ះពាល់ដោយគ្រឿងស្រវឹង អង្គការឡៃហ្វ៍រដីវើល និងវិស័យឯកជន បាននិងកំពុងអនុវត្តនៅរាជធានី ខេត្តចំនួន១១ មានខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កណ្ដាល កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ពោធិ៍សាត់ ព្រះសីហនុ និងរាជធានីភ្នំពេញ ក្នុងស្រុក/ក្រុង/ខណ្ឌចំនួន១១ ឃុំ/សង្កាត់ចំនួន២៤ ភូមិចំនួន១៤៥ ក្លឹបយុវជនចំនួន៥៨ គ្រឹះស្ថានឧត្តមសិក្សាចំនួន១០ ក្រុមប្រតិបត្តិករគម្រោងមានទីប្រឹក្សាយុវជន យុវជន និងអ្នកស្ម័គ្រចិត្តសរុបចំនួន **៣,៤៧៥នាក់**។ លទ្ធផលសម្រេចបាន រួមមាន ៖

✓ ផ្ដល់វគ្គបណ្ដុះបណ្ដាលសមត្ថភាព ជូនគ្រូបង្គោលសុវត្ថិភាពចរាចរណ៍ចំនួន**១៥នាក់** នៅតាមសាខាកាកបាទក្រហមកម្ពុជាខេត្តសៀមរាប ព្រៃវែង និងព្រះសីហនុ ដើម្បីជួយបណ្ដុះបណ្ដាលបន្តទៅដល់ក្រុមយុវជន អ្នកស្ម័គ្រចិត្ត និងក្រុមគោលដៅពាក់ព័ន្ធផ្សេងទៀត។




យុវជន កក្រក ចុះផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍នៅតាមទីសាធារណៈ ក្នុងពេលពិធីបុណ្យជាតិ

✓ ផ្ដល់វគ្គបណ្ដុះបណ្ដាលសមត្ថភាព ជូនជនបង្គោលសុវត្ថិភាពចរាចរណ៍ ជាយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមចំនួន **២៦០នាក់** នៅតាមសាខាគោលដៅទាំង១១ និងជនបង្គោលនៅតាម ក្រសួង មន្ទីរ និងស្ថាប័នពាក់ព័ន្ធក្នុងខេត្តព្រៃវែង កំពង់ចាម ព្រះសីហនុ និងសៀមរាបចំនួន **១២០នាក់**។

✓ គ្រូបង្គោលប្រចាំសាខា បានបណ្ដុះបណ្ដាលសុវត្ថិភាពចរាចរណ៍ អំពីមួកសុវត្ថិភាព គ្រឿងស្រវឹង ការបើកបរលើសល្បឿនកំណត់ ផ្ទុកលើសចំណុះ និងការបញ្ជ្រាបពិការភាព ជូនយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១៧វគ្គ** មានអ្នកចូលរួមចំនួន **៤៤១នាក់**។

- ✓ ផ្តល់វគ្គបំប៉នសមត្ថភាពបន្ថែម អំពីសុវត្ថិភាពចរាចរណ៍ ផ្តោតលើហានិភ័យ នៃគ្រឿងស្រវឹង ជូនមន្ត្រីនគរបាលចរាចរណ៍ចំនួន **១៥០នាក់** មកពីខេត្តសៀមរាប ព្រះសីហនុ និងព្រៃវែង។
- ✓ បានចូលរួមពិនិត្យ ពិភាក្សា អំពីការងារសុវត្ថិភាពចរាចរណ៍ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ/សង្កាត់ចំនួន៤ នៅខេត្តពោធិ៍សាត់ និងសៀមរាប។
- ✓ បានផ្សព្វផ្សាយ អំពីសុវត្ថិភាពចរាចរណ៍នៅតាមអនុវិទ្យាល័យ/វិទ្យាល័យចំនួន **៥៨** គ្រឹះស្ថានឧត្តមសិក្សាចំនួន **១០** មានអ្នកចូលរួមសរុបចំនួន **៨,២៤០នាក់** និងនៅតាមឃុំ/សង្កាត់ចំនួន **២៤ឃុំ**និង **១៤៥ភូមិ** មានប្រជាពលរដ្ឋចូលរួមសរុប **២៤,៣៩៦នាក់**។
- ✓ បានរៀបចំយុទ្ធនាការអប់រំសុវត្ថិភាពចរាចរណ៍ក្នុងឱកាសបុណ្យជាតិ អន្តរជាតិ និងតាមទីសាធារណៈ ចំនួន ៦លើក ក្នុងខេត្តសៀមរាប កំពង់ស្ពឺ កំពង់ចាម និងរាជធានីភ្នំពេញ។




*មន្ត្រីគម្រោង ម្ចាស់ជំនួយ យុវជន កក្រក ប៉ូលីសចរាចរណ៍ និងភាគីពាក់ព័ន្ធក្នុងថ្ងៃយុទ្ធនាការអប់រំសុវត្ថិភាពចរាចរណ៍*

## II. ទិសយុទ្ធសាស្ត្រទី២ ÷ *រួមចំណែកកាត់បន្ថយអត្រាឈឺ និងស្លាប់នៃមាតា និងកុមារការពារជំងឺឆ្លងនិងអន្តរាគមន៍សុខភាពគ្រាអាសន្ន*

### វិស័យស្នូលទី២ ៖ សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍

វិស័យស្នូលសុខភាព និងការថែទាំសុខភាពក្នុងសហគមន៍ ពិតជាវិស័យស្នូល១ ដែលតម្រូវឱ្យកាកបាទក្រហមកម្ពុជា ធ្វើឱ្យបានកាន់តែច្រើនជាងមុនជារៀងរហូត។ ឆ្នាំនេះពាក់ព័ន្ធនឹងការងារឥស្សរជនឆ្នើមថ្នាក់ជាតិកាន់តែត្រូវបានបញ្ជ្រាបក្នុងគ្រប់សកម្មភាពទាំងអស់របស់ទីស្នាក់ការកណ្តាល និងសាខា មិនថាក្រុមប្រតិបត្តិ ឬគណៈអភិបាល នៃសាខា បានចូលរួមយ៉ាងសកម្មលើកកម្ពស់សុខភាព របស់ប្រជាពលរដ្ឋ។ វិស័យស្នូលនេះមានសកម្មភាពចំនួន២ និងគម្រោងចំនួន៥ ដោយថវិកាកាកបាទក្រហមកម្ពុជា និងដៃគូចំនួន៥។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០១៦ នេះ មានដូចតទៅ ៖

### *សកម្មភាពទី១៖ ការងារឥស្សរជនឆ្នើមថ្នាក់ជាតិ*

១. បានរៀបចំសារលិខិត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ផ្ញើជូនជនរួមជាតិក្នុងឱកាសទិវាជាតិ និងអន្តរជាតិចំនួន៣ រួមមានទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ កុម្ភៈ ទិវាឆ្មបជាតិ ថ្ងៃទី៥ ឧសភា និងទិវា

ប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ថ្ងៃទី១ ធ្នូ ឆ្នាំ២០១៦ ដោយបានផ្សព្វផ្សាយតាមទូរទស្សន៍ទាំង៦ប៉ុស្តិ៍ នៅថ្នាក់កណ្តាល និងបានផ្ញើជូនសាខាទាំង ២៥ រាជធានី-ខេត្ត ដើម្បីបន្តធ្វើសកម្មភាព។

**២.** បានរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៦ នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ក្រោមប្រធានបទ "**យុវជនកម្ពុជាប្តេជ្ញា រួមចំណែកការពារមិនឱ្យឆ្លងអេដស៍**" ឆ្លើយតបការងារគស្សរជនផ្តើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីកាកបាទក្រហមកម្ពុជា សាស្ត្រាចារ្យ និស្សិត យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១៥០នាក់**។




*លោកជំទាវអនុប្រធាន កក្រក ចុះសួរសុខទុក្ខ និងរៀបចំអាហារជូន ចាស់ជរា កុមារ និងអ្នកមានជំងឺប្រចាំកាយ នៅមណ្ឌលសង្គ្រោះជនអស់សង្ឃឹម និងយុវជនចូលរួមឆ្លើយសំណួរក្នុងវេទិកាកិច្ចពិភាក្សាទស្សនៈ យុវជន នៅថ្ងៃទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ*

**៣.** សាខា កក្រក ទាំ២៥ រាជធានី ខេត្ត បានបញ្ជ្រាបសារសុខភាព **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ក្នុងគ្រប់សកម្មភាពទាំងអស់ មិនថាជាសកម្មភាពដោយប្រើថវិកាផ្ទាល់របស់សាខា ឬរបស់ដៃគូឡើយ។

ជាងនេះទៀត ក្រោមការចង្អុលបង្ហាញ និងណែនាំជាប្រចាំពី **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** មន្ត្រីប្រតិបត្តិនៅថ្នាក់កណ្តាល បានចុះសួរសុខទុក្ខ និងផ្តល់អំណោយ ជូនជនងាយរងគ្រោះ និងរងគ្រោះ ជាបន្តបន្ទាប់ដូចជា ៖

- ផ្តល់ថវិកាចំនួន **១លានដុល្លារ** ជូនមន្ទីរពេទ្យគន្ធបុប្ផា ឆ្នាំនេះជាឆ្នាំទី៥ហើយ។




*សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន កក្រក ប្រគល់មូលប្បទានប័ត្រ ១លានដុល្លារ ជូនប្រធានមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីចូលរួមសម្រាលការលំបាករបស់មន្ទីរពេទ្យ ក្នុងការលើកកម្ពស់សុខភាពកុមារនៅកម្ពុជា*

- ផ្តល់ថវិកាចំនួន **៦៨,០៦០ដុល្លារ** ជូនអង្គការលើកស្ទួយប្រជាពលរដ្ឋ សម្រាប់សាងសង់អគារសិក្សា និងទិញគ្រឿងសម្ភារៈបំពាក់ក្នុងអគារ។

- ផ្តល់ថវិកាចំនួន **៥ម៉ឺនដុល្លារ** ជូនអង្គការជំនួយនៃក្តីសង្ឃឹមសម្រាប់សហគមន៍ ដើម្បីសាងសង់មណ្ឌលស្នាក់នៅ និងបណ្តុះបណ្តាល សម្រាប់កុមារខ្សោយសតិបញ្ញាចំនួន **៧០នាក់** ស្រុកស្អាង ខេត្តកណ្តាល។
- ផ្តល់ថវិកាចំនួន **២០លានរៀល**និង **១ម៉ឺនដុល្លារ** ជូនអង្គការគ្រួសារថ្មី ដើម្បីជួយសម្រួលការលំបាកក្នុងជីវភាពប្រចាំថ្ងៃក្នុងមជ្ឈមណ្ឌល និងចំនួន **២០លានរៀល** ជូនអង្គការសង្គ្រោះជនអស់សង្ឃឹម។
- ផ្តល់ថវិកាចំនួន **១ម៉ឺន៣ពាន់ដុល្លារ** ជូនបងប្អូនខ្មែរ-ឥស្លាម សម្រាប់សាងសង់ទីលានបាល់ទាត់នៅស្រុកពាមរក៍ ខេត្តព្រៃវែង។
- បានសួរសុខទុក្ខ និងផ្តល់អំណោយ ជូនអ្នករស់នៅជាមួយមេរោគអេដស៍ ជំងឺអេដស៍សរុប **២,៨៥៧នាក់** ស្ត្រីមានផ្ទៃពោះ និងសម្រាលកូនតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យសរុប **៥,១៨៨នាក់**។
- បានសួរសុខទុក្ខ និងសំណេះសំណាលនាំយកសម្ភារៈសិក្សា នំចំណី ទឹកបរិសុទ្ធ និងថវិកា ជូនកុមារសាលាមត្តេយ្យសហគមន៍ និងលោកគ្រូអ្នកគ្រូសរុបចំនួន **២១៣នាក់** នៅឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល ក្នុងទិវាកុមារអន្តរជាតិ ១មិថុនា ខួបទី៦៧ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២ មិថុនា ខួបទី១៥ ។

## *សកម្មភាពទី២៖ ការលើកកម្ពស់សុខភាពមាតា ទារក និងកុមារ*

សកម្មភាពទី២នេះ មានគម្រោងចំនួន៥ ដៃគូចំនួន៥ អនុវត្តនៅខេត្តគោលដៅចំនួន១៣ ស្រុកចំនួន១៥ ឃុំចំនួន៣២ និងភូមិចំនួន១៣៧ មានអ្នកទទួលផលសរុបចំនួន**១០១,៤៨០គ្រួសារ**។ លទ្ធផលសម្រេចបានដូចខាងក្រោម ៖

**១. គម្រោងអភិវឌ្ឍសុខភាពសហគមន៍មូលដ្ឋាន** ឧបត្ថម្ភដោយកាកបាទក្រហមដាណឺម៉ាក បានអនុវត្តនៅខេត្តព្រះវិហារ និងកំពត ក្នុងស្រុកចំនួន៥ ឃុំចំនួន៩ ភូមិចំនួន៤៧ អនុវត្តដោយអ្នកស្ម័គ្រចិត្តចំនួន **៣២២នាក់** និងមានអ្នកទទួលផលសរុបចំនួន **៤៦,៩៩០គ្រួសារ**។ លទ្ធផលសម្រេចបានមាន ៖ (គម្រោងបានបញ្ចប់នៅខែមិថុនា ២០១៦)

- ផ្តល់បង្គន់គ្រួសារចំនួន **២៤០គ្រួសារ** និងកន្លែងលាងសម្អាតដៃចំនួន **៥៣៥កន្លែង**។
- ផ្តល់សម្ភារៈដូចជាកាតាប សៀវភៅ និងប៊ិច ជូនអ្នកស្ម័គ្រចិត្តចំនួន **១៤៩នាក់** និងផ្តល់សម្ភារៈបម្រើសេវាសម្រាលកូន និងសេវា ចុះមូលដ្ឋាន ជូនមណ្ឌលសុខភាពក្នុងឃុំ គោលដៅ។
- បានយកទឹកអណ្តូងចំនួន ៣៧លើក មកពិនិត្យគុណភាពទឹកនៅមន្ទីរពិសោធន៍រាជធានីភ្នំពេញ។
- បានរៀបចំទិវាទឹកពិភពលោក និងចាក់រឿងអប់រំសុខភាពអំពីអនាម័យ និងទឹកស្អាត ជូនប្រជាពលរដ្ឋចំនួន **១,៤៨៥នាក់** (ស្រី៩៦២នាក់)។


*ការពិនិត្យគុណភាពទឹកអណ្តូង និង ប្រគល់សម្ភារៈបរិក្ខាជូនមណ្ឌលសុខភាព*

- ផ្តល់វគ្គបណ្តុះបណ្តាល អំពីការជួសជុល និងថែទាំអណ្តូងទឹក ជូនក្រុមប្រើប្រាស់ទឹកចំនួន **៧១អណ្តូង** មានអ្នកចូលរួមចំនួន **១៥៩នាក់** (ស្រី៦៥នាក់) និងចុះដាក់ក្លរសម្លាប់មេរោគក្នុងអណ្តូងចំនួន **៧៣កន្លែង** នៅឃុំដានគោម ដំណាក់សុក្រំ និងព្រៃថ្នង ខេត្តកំពត។






*សហគមន៍ចូលរួមជួសជុលអណ្តូងស្នប់ និងក្លឹបស្ត្រីប្រជុំប្រចាំខែដោយមានការសម្របសម្រួលពីមន្ត្រីគម្រោង*

- ផ្តល់វគ្គបំប៉នសមត្ថភាព អំពីវិជ្ជាសង្គ្រោះបឋម អនាម័យទឹកស្អាត និងសុខភាពមាតា ទារក និងកុមារ ជូនអ្នកស្ម័គ្រចិត្តនៅភូមិ ឃុំគោលដៅទាំងអស់ ដើម្បីជួយផ្សព្វផ្សាយបន្តនៅតាមសហគមន៍។
- រៀបចំយុទ្ធនាការសម្អាតបរិស្ថានចំនួន ១លើក មានអ្នកចូលរួមចំនួន **៤៦៥នាក់** (ស្រី៣៧៦នាក់)។
- បានចុះអប់រំផ្សព្វផ្សាយ អំពីអនាម័យបរិស្ថាន ការចាក់ថ្នាំបង្ការគ្រុនចាញ់ និងការបំបៅដោះកូនដោយទឹកដោះម្តាយ ជូនប្រជាពលរដ្ឋនៅតាមផ្ទះចំនួន **១៤,៩២៧នាក់** (ស្រី១២,៣៧៣នាក់)។
- អ្នកស្ម័គ្រចិត្តជួយសង្គ្រោះបឋមបានចំនួន **១,៩៧៨ករណី** និងផ្តល់សម្ភារៈសង្គ្រោះបឋម ជូនអ្នកស្ម័គ្រចិត្តចំនួន **៣១២សម្រាប់**។

២. **គម្រោងកសាងភាពធន់ក្នុងសហគមន៍** ឧបត្ថម្ភដោយកាកបាទក្រហមហ្វាំងឡង់ បាននិងកំពុងអនុវត្ត នៅខេត្តត្បូងឃ្មុំ ក្នុងស្រុកចំនួន២ ឃុំចំនួន៤ ភូមិចំនួន១២ អនុវត្តដោយយុវជនចំនួន **២៥នាក់** និងអ្នកស្ម័គ្រចិត្តចំនួន **១៥០នាក់** មានអ្នកទទួលផលសរុបចំនួន **២,៩៤៧គ្រួសារ**។ លទ្ធផលសម្រេចបាន រួមមាន ៖

- ផ្តល់បង្គន់អនាម័យគ្រួសារចំនួន **២៣៥** ជូនប្រជាពលរដ្ឋក្នុងភូមិគោលដៅក្នុងខេត្តត្បូងឃ្មុំ នៅឆ្នាំ២០១៦។
- ផ្តល់ឡដុតសំរាមចំនួន ២ ធុងសំរាមចំនួន ៦ និងកន្លែងលាងដៃចំនួន ៥កន្លែង ដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូសរុបចំនួន ៥២៥នាក់ នៃសាលាគោលដៅវិទ្យាល័យ ហ៊ុនសែន ព្រៃកអាជី ស្រុកក្រូចឆ្មារ។
- អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន ១៥០នាក់ និងប្រជាពលរដ្ឋចំនួន ៦២៤នាក់ បានចូលរួមសម្អាត ទីធ្លាផ្ទះ ទីសាធារណៈ (វត្តអារាម តាមដងផ្លូវ ទីធ្លាសាលារៀន...) ចំនួន ១៦កន្លែង។
- ផ្តល់វគ្គបណ្តុះបណ្តាលមូលដ្ឋាន អំពីសុខភាពសហគមន៍ វិជ្ជាសង្គ្រោះបឋម និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ជូនអ្នកស្ម័គ្រចិត្តចំនួន ១៥០នាក់ (ស្រី៧៧នាក់) និងយុវជនកាកបាទក្រហមចំនួន ២៥នាក់ (ស្រី១៦នាក់) ដើម្បីជួយផ្សព្វផ្សាយបន្តនៅតាមសហគមន៍ និងសាលារៀន។





*យុវជន និងអ្នកស្ម័គ្រចិត្ត កក្រក ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាសុខភាពក្នុងសហគមន៍ និងវិជ្ជាសង្គ្រោះបឋម ដើម្បីទៅផ្សព្វផ្សាយបន្ត*

- សហការសម្របសម្រួលជាមួយ សាខាកាកបាទក្រហមកម្ពុជាខេត្តត្បូងឃ្មុំ មន្ទីរកសិកម្ម និងមន្ទីរសុខាភិបាល រៀបចំវគ្គពង្រឹងសមត្ថភាព ជូនអ្នកស្ម័គ្រចិត្តចំនួន **១៥០នាក់** (ស្រី៧៧នាក់) អំពីបញ្ហាអាទិភាពនៃសុខភាព គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- រៀបចំទិវាអន្តរជាតិនៃអ្នកស្ម័គ្រចិត្តដោយមានអ្នកចូលរួមសរុបចំនួន ៣០០នាក់ (ស្រី១៨០នាក់) រួមមាន គណៈកម្មាធិការសាខា ក្រុមប្រតិបត្តិសាខា ក្រុមប្រតិបត្តិគម្រោង គណៈកម្មាធិការអនុសាខាស្រុកត្បូងឃ្មុំ យុវជនកាកបាទក្រហម អ្នកស្ម័គ្រចិត្តកាកបាទក្រហម អាជ្ញាធរភូមិឃុំ ដោយផ្តល់បណ្ណសរសើរ រង្វាន់លើកទឹកចិត្ត និងអាហារសាមគ្គីរួមគ្នា នៅសាលាឃុំជីពាទី១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។




*ប្រធានគណៈកម្មាធិការផ្តល់ប័ណ្ណសរសើរ និង មួកសុវត្ថិភាពជូនអ្នកស្ម័គ្រចិត្ត ក្នុងពិធីទិវាអ្នកស្ម័គ្រចិត្តអន្តរជាតិនៅខេត្តត្បូងឃ្មុំ*

- ក្រុមប្រតិបត្តិសាខា និងគម្រោង យុវជនកាកបាទក្រហម និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមក្នុងតំបន់គោលដៅសរុបទាំងអស់ ២៥នាក់ (ស្រី៤នាក់) បានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍នៅសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ។
- អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន ១៥០នាក់ ក្នុងភូមិគោលដៅទាំង ១២ បានអប់រំផ្សព្វផ្សាយ អំពីការបញ្ឈប់ចម្លងមេរោគដោយលាងដៃជាមួយសាប៊ូ ជូនប្រជាពលរដ្ឋចំនួន **២,៧៤៣**នាក់ (ស្រី១,៦៤៧នាក់) ព្រមទាំងផ្តល់សាប៊ូចំនួន ៩៧២ដុំ និងកន្ត្រៃកាត់ក្រចកចំនួន ១,៧៧១កន្ត្រៃ ដល់អ្នកចូលរួមទាំងអស់។
- រៀបចំបង្កើតក្លឹបយុវជនកាកបាទក្រហមនៅសាលាគោលដៅវិទ្យាល័យ ហ៊ុនសែន ព្រែកអាជី ស្រុកក្រូចឆ្មារ ដោយគម្រោងផ្តល់ឲ្យឯកសណ្ឋានយុវជនកាកបាទក្រហមកម្ពុជាចំនួន ២៧សម្រាប់ និងបំពាក់សម្ភារៈបរិក្ខារមួយចំនួនទៀត ដើម្បីដំណើរការក្លឹប។

**៣. គម្រោងអភិវឌ្ឍន៍សុខភាពសហគមន៍មូលដ្ឋាន** ឧបត្ថម្ភដោយកាកបាទក្រហមអូស្ត្រាលី បានអនុវត្តនៅខេត្តសៀមរាប បាត់ដំបង ព្រះវិហារ និងកោះកុង ក្នុងស្រុកចំនួន៨ ឃុំចំនួន២០ ភូមិចំនួន៣៨ អនុវត្តដោយអ្នកស្ម័គ្រចិត្តចំនួន **១៣៦នាក់** និងមានអ្នកទទួលផលសរុបចំនួន **៣៣,៣៤៩គ្រួសារ**។ លទ្ធផលសម្រេចបាន រួមមាន៖ (គម្រោងបានបញ្ចប់នៅខែមិថុនា ២០១៦)

- ផ្តល់បង្គន់អនាម័យគ្រួសារចំនួន **២៩** និងតាមសាលារៀន ជូនប្រជាពលរដ្ឋក្នុងសហគមន៍ និងសម្ភារៈអនាម័យចំនួន **២២កញ្ចប់** ជូនសាលារៀនគោលដៅទាំង៦។



*មន្ត្រីពិនិត្យការសាងសង់បង្គន់អនាម័យតាមសាលានៅខេត្តបាត់ដំបង និងសិស្សកំពុងអនុវត្តការលាងដៃ នៅសាលាក្នុងខេត្តកោះកុង*

- ផ្តល់អណ្តូងទឹកចំនួន ៨អណ្តូង ជូនប្រជាពលរដ្ឋក្នុងសហគមន៍ និងចំនួន ១អណ្តូង ជូនសាលារៀន។
- ផ្តល់កញ្ចប់អាហារូបត្ថម្ភ ជូនកុមារ **១២០កញ្ចប់** បញ្ជូនស្ត្រីមានផ្ទៃពោះចំនួន **១៥៥នាក់** ទៅពិនិត្យសុខភាព និងបញ្ជូនកុមារអាយុក្រោម៥ឆ្នាំចំនួន **៣៣៤នាក់** ទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាព។
- បានចុះអប់រំផ្សព្វផ្សាយ អំពីអនាម័យការប្រើប្រាស់ទឹក សម្អាតបរិស្ថាន និងការលាងសម្អាតដៃ ជូនប្រជាពលរដ្ឋ និងសិស្សានុសិស្សចំនួន **២,២៦៦នាក់**។
- អ្នកស្ម័គ្រចិត្តនៅតាមភូមិគោលដៅ បានចុះសួរសុខទុក្ខ និងអប់រំ អំពីសុខភាពអនាម័យ ជូនប្រជាពលរដ្ឋចំនួន **៧,៦៥០នាក់**។
- រៀបចំយុទ្ធនាការ ឬទិវាសំខាន់ៗ រួមមានទិវាទឹកពិភពលោក "**ទឹក និងការងារ**" និងទិវាសម្អាតភូមិបាន **៨ដង** មានអ្នកចូលរួម**ចំនួន ៤៤៩នាក់**។

**៤. គម្រោងបង្កើននិរន្តរភាព នៃការប្រើប្រាស់ទឹកស្អាត និងអនុវត្តអនាម័យ** ឧបត្ថម្ភដោយសហព័ន្ធអន្តរជាតិ បាននិងកំពុងអនុវត្តនៅខេត្តក្រចេះ ស្វាយរៀង និងបន្ទាយមានជ័យ ក្នុងស្រុក/ក្រុងចំនួន៣ ឃុំចំនួន៧ ភូមិចំនួន៣៣ អនុវត្តដោយយុវជនចំនួន **១០០នាក់** អ្នកស្ម័គ្រចិត្តចំនួន **៩៦នាក់** និងមានអ្នកទទួលផលសរុបចំនួន **១៩,៤៦២គ្រួសារ**។ លទ្ធផលសម្រេចបាន រួមមាន៖

- ផ្តល់បង្គន់អនាម័យគ្រួសារចំនួន **៣៨៩បង្គន់** អណ្តូងស្នប់ចំនួន **១០អណ្តូង** (មានជម្រៅពី៣០ម៉ែត្រ ដល់៣០០ម៉ែត្រ) ប្រព័ន្ធទឹកស្អាតចំនួន **២សម្រាប់** ម៉ាស៊ីនចម្រោះទឹកស្អាតចំនួន **៦គ្រឿង** សម្ភារៈអនាម័យ ចំនួន **២៤កញ្ចប់**។



*លោកជំទាវអគ្គលេខាធិការរងទី១ កក្រក ក្នុងពិធីប្រគល់ស៊ីទែនទឹក និងប្រព័ន្ធបូមទឹកដើរដោយថាមពលពន្លឺព្រះអាទិត្យនៅខេត្តស្វាយរៀង*

- កែលម្អស្រះទឹកចាស់សហគមន៍ចំនួន១ (ទំហំ៥០x៣០ម៉ែត្រ និងជម្រៅ៥ម៉ែត្រ) មានអ្នកទទួលផលចំនួន **១៦៧គ្រួសារ** នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងចំនួន៣ (ទំហំ២៣x១២ម៉ែត្រ និងជម្រៅ២,៥ម៉ែត្រ) មានអ្នកទទួលផលចំនួន **២៣៦គ្រួសារ** នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង។



ស្រះទឹកសហគមន៍ដែលបានស្ដារួច នៅស្រុកចន្ទ្រា ខេត្តស្វាយរៀង និងអណ្ដូងទឹកអាហ្វ្រីដេសនៅចិត្របុរី ខេត្តក្រចេះ

- បានប្រគល់ម៉ូតូ១គ្រឿង កុំព្យូទ័រ១គ្រឿង ព្រីនធ័រ១គ្រឿង និងម៉ាស៊ីនថត១គ្រឿង ជូនសាខាកាកបាទក្រហមកម្ពុជា ខេត្តបន្ទាយមានជ័យ ដើម្បីបម្រើសកម្មភាព សុខភាពអនាម័យទឹកស្អាត។
- ផ្ដល់វគ្គបំប៉ន អំពីអនាម័យទឹកស្អាត ការថែទាំបង្គន់អនាម័យ ការប្រែប្រួលអាកាសធាតុ គោលការណ៍គ្រឹះរបស់ចលនា វិជ្ជាសង្គ្រោះបឋម និងជំងឺផ្សេងៗដែលកើតឡើងដោយទឹក ជូនយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **៥៧នាក់** ដើម្បីជួយផ្សព្វផ្សាយបន្ត។
- អ្នកស្ម័គ្រចិត្ត បានចុះសួរសុខទុក្ខ និងអប់រំផ្សព្វផ្សាយ អំពីអនាម័យសុខភាព ការប្រើប្រាស់ថែទាំបង្គន់ ជូនប្រជាពលរដ្ឋ និងសិស្សានុសិស្សចំនួន **៤,៤៥៧នាក់** និងជួយសង្គ្រោះបឋមបានចំនួន **៨៨នាក់**។
- រៀបចំយុទ្ធនាការ ឬទិវាសំខាន់ៗ រួមមានទិវាទឹកពិភពលោក "**ទឹក និងការងារ**" និងទិវាសម្អាតភូមិបាន **៨ដង** មានអ្នកចូលរួមចំនួន **៣១១នាក់**។

**៥. គម្រោងវិជ្ជាសង្គ្រោះបឋម** ជារៀងរហូតមក បានអនុវត្តការងារចំនួន ២ គឺការបណ្ដុះបណ្ដាលភ្នាក់ងារសង្គ្រោះបឋម គ្រូបង្រៀនវិជ្ជាសង្គ្រោះបឋម និងការផ្សព្វផ្សាយវិជ្ជាសង្គ្រោះបឋមឱ្យអ្នកទទួលផលមានចំណាប់អារម្មណ៍ស្គាល់ ហើយចង់ចេះដឹងជំនាញ និងអាចផ្ដល់សេវាសង្គ្រោះបឋមសាមញ្ញៗបាន។ ឆ្នាំនេះ ការអនុវត្តតាមអនុសាសន៍ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ បានផ្ដោតលើការបណ្ដុះបណ្ដាល អត់បង់ថ្លៃច្រើនជាងចំនួន **២៦វគ្គ** និងអ្នកចូលរួមចំនួន **១,៣៧៧នាក់**។ គម្រោងនេះ នៅមានដៃគូចំនួន ២ ឧបត្ថម្ភគាំទ្រ គឺកាកបាទក្រហមជប៉ុន និងកាកបាទក្រហមដាណឺម៉ាក។ លទ្ធផលសម្រេចបាន រួមមាន៖



មន្ត្រីគម្រោងនិងអ្នកស្ម័គ្រចិត្ត កំពុងបង្ហាញការអនុវត្តមេរៀនសង្គ្រោះបឋមជូនបុគ្គលិកក្រុមហ៊ុន និងសហគមន៍នៅខេត្តកំពង់ធំ

- **ដោយថវិកាកាកបាទក្រហមកម្ពុជា** បាននិងកំពុងអនុវត្តនៅរាជធានី ខេត្តទាំង២៥ ដោយផ្ដល់វគ្គបណ្ដុះបណ្ដាលវិជ្ជាសង្គ្រោះបឋមបង់ថ្លៃចំនួន **៤៦វគ្គ** មានអ្នកចូលរួមចំនួន **៨៦១នាក់** ទទួលបានថវិកាចំនួន **២៨,៣០៣.៤៨ដុល្លារ**។ ដោយឡែកមានសាខាកាកបាទក្រហមកម្ពុជាចំនួន ៣ បានបើកវគ្គបង់ថ្លៃ

ចំនួន **៤៩វគ្គ** មានអ្នកចូលរួមចំនួន **១,០៥៥នាក់** ទទួលបានថវិកាចំនួន **២១,៦៥០ដុល្លារ** ដើម្បីរក្សានិរន្តរភាពការងារបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋម។

- **ដោយកាកបាទក្រហមជប៉ុន** (ជាឆ្នាំទី៨) បាននិងកំពុងអនុវត្តនៅរាជធានី ខេត្តចំនួន៤ ក្នុងស្រុក/ខណ្ឌចំនួន៤៣ ឃុំ/សង្កាត់ចំនួន១៧ ភូមិចំនួន១៨៦ អនុវត្តដោយយុវជនចំនួន **១០០នាក់** និងអ្នកស្ម័គ្រចិត្តចំនួន **២០០នាក់** មានអ្នកទទួលផលសរុបចំនួន **៤៣,២៥០គ្រួសារ** រួមមាន៖
  - ✓ ផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមមូលដ្ឋាន ជូនយុវជន អ្នកស្ម័គ្រចិត្ត បុគ្គលិក មន្ត្រីរាជការ កម្មករបានចំនួន **១២៨វគ្គ** មានអ្នកចូលរួមចំនួន **៥,៧២៨នាក់** (ស្រី៣,១៩៦នាក់)។
  - ✓ ក្រុមយុវជនចំនួន **១០០នាក់** និងអ្នកស្ម័គ្រចិត្តចំនួន **២០០នាក់** បានផ្សព្វផ្សាយ ជូនសិស្សានុសិស្ស ប្រជាពលរដ្ឋចំនួន **២០,៤២០នាក់** និងផ្តល់សេវាសង្គ្រោះបឋម និងបញ្ជូនជនរងគ្រោះចំនួន **៣,៩៨៨នាក់**។
- **ដោយកាកបាទក្រហមដាណឺម៉ាក** បាននិងកំពុងអនុវត្តនៅវិទ្យាល័យចំនួន **១៥** សាកលវិទ្យាល័យចំនួន **២០** ក្នុងរាជធានីភ្នំពេញ ដោយបានផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមមូលដ្ឋាន ជូនគ្រូបង្គោលចំនួន **៣៤នាក់** និងសិស្ស និស្សិតចំនួន **៣០**វគ្គ មានអ្នកចូលរួមចំនួន**៨៨៩នាក់** ដើម្បីជួយផ្សព្វផ្សាយបន្ត។

## III. ទិសយុទ្ធសាស្ត្រទី៣ ÷ *លើកកម្ពស់គោលការណ៍គ្រឹះ តម្លៃមនុស្សធម៌ សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិនិងវប្បធម៌អហិង្សា*

### ទិស័យស្នូលទី៣ ៖ ការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា

ឆ្នាំ២០១៦ កាកបាទក្រហមកម្ពុជា បានខិតខំប្រឹងប្រែងយកអស់លទ្ធភាពក្នុងការងារពង្រីក ពង្រឹងលើកកម្ពស់យល់ដឹង អំពីគោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌តាមរយៈការបណ្តុះបណ្តាលយុវជន អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា រួមទាំងកម្លាំងប្រដាប់អាវុធផង ការផ្សព្វផ្សាយជាប្រចាំនៅតាមទូរទស្សន៍ទាំង ៦ និងបណ្តាញព័ត៌មានសង្គម តាមសកម្មភាពគ្រប់យ៉ាង នៃវិស័យស្នូលទាំង ៤ ជាពិសេសតាមរយៈព្រឹត្តិការណ៍ធំៗ របស់កាកបាទក្រហមកម្ពុជា ដូចជាទិវា ៨ឧសភា ជាដើម។ គ្រប់សកម្មភាព និងការផ្សព្វផ្សាយទាំងអស់ កាន់តែបង្ហាញច្បាស់ អំពីការអនុវត្តត្រឹមត្រូវតាមគោលការណ៍គ្រឹះ និងចំមុខសញ្ញាដែលត្រូវការឱ្យជួយ។ ដើម្បីសម្រេចបានតាមទិសយុទ្ធសាស្ត្រទី៣ នេះក្នុងសកម្មភាពទាំង ៥ កាកបាទក្រហមកម្ពុជា សម្រេចលទ្ធផលបាន ដូចខាងក្រោម៖

*សកម្មភាពទី១ ៖ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០១៦*



*សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន ថ្លែងសុន្ទរកថានាទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា*

- ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៦ ខួបទី១៥៣ ក្រោមប្រធានបទ "**កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា**" បានប្រារព្ធនៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានការចូលរួម និងគាំទ្រពីភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សប្បុរសជន មហាជន យុវជន អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា យ៉ាងច្រើនកុះករ។ ជាមួយគ្នានេះការប្រារព្ធមិទ្ទីញ និងរាត្រីសមោសរនៅតាមសាខា ក៏បានប្រព្រឹត្តទៅតាមលទ្ធភាពរៀងៗខ្លួន ក្រោមអធិបតីភាពឯកឧត្តមប្រធានកិត្តិយស ឥស្សរជនជាន់ខ្ពស់របស់សាខា និងបានទទួលការចូលរួមឧបត្ថម្ភគាំទ្រទាំងថវិកា និងសម្ភារៈពីគ្រប់មជ្ឈដ្ឋានកាន់តែប្រសើរឡើង។ ជាពិសេសចំណូល នៅតាមសាខានីមួយៗ មានការកើនឡើងគួរឲ្យកត់សម្គាល់។



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន ដឹកនាំសមាជិកគណៈកម្មាធិការកណ្តាល និងក្រុមប្រតិបត្តិ ចូលបង្គំគាល់ព្រះប្រធានកិត្តិយស កក្រក និងថ្វាយរបាយការណ៍វឌ្ឍនភាពរបស់ កក្រក ៦ខែ ដើមឆ្នាំ២០១៦*

- **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** បានដឹកនាំសមាជិក សមាជិកាគណៈកម្មាធិការកណ្តាល និងថ្នាក់ដឹកនាំក្រុមប្រតិបត្តិ ចូលក្រាបបង្គំគាល់ទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ដើម្បីគោរព និងក្រាបបង្គំទូលថ្វាយ នូវរបាយការណ៍សកម្មភាពការងារកាកបាទក្រហមកម្ពុជា ពីដើមឆ្នាំរហូតដល់ក្រោយទិវា ៨ឧសភា។

## សកម្មភាពទី២ ៖ លើកកម្ពស់ការផ្សព្វផ្សាយអំពីចលនាគោលការណ៍គ្រឹះ និងច្បាប់មនុស្សធម៌អន្តរជាតិ



*យុវជន កក្រក ចូលរួមឆ្លើយសំណួរក្នុងវេទិកាយុវជនស្តីពី "យុវជន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក"*

- រៀបចំវេទិកាយុវជន អំពី "**យុវជន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក**" នៅស្តូឌីយោទូរទស្សន៍ជាតិកម្ពុជា មានការចូលរួមពីទីប្រឹក្សាយុវជន និងយុវជនកាកបាទក្រហមកម្ពុជាចំនួន **១៧០នាក់** មកពីសកលវិទ្យាល័យភ្នំពេញអន្តរជាតិ សកលវិទ្យាល័យកម្ពុជា សកលវិទ្យាល័យមេគង្គកម្ពុជា និងសកលវិទ្យាល័យ ភូមិន្ទភ្នំពេញ។



*ការប្រឡងគំនូរកុមារអំពីសកម្មភាពចម្រុះវិស័យរបស់ កក្រក និងការផ្តល់រង្វាន់ជ័យលាភីដល់សិស្សានុសិស្ស ដែលជាប់ចំណាត់ថ្នាក់*

- រៀបចំពិធីប្រគល់រង្វាន់ជ័យលាភីថ្នាក់ជាតិគំនូរកុមារទូទាំងប្រទេសចំនួន **១០៨គំនូរ** ក្នុងនោះមានកុមារទទួលជ័យលាភីចំនួន **៥នាក់** និងរង្វាន់លួងចិត្តចំនួន **១០៣នាក់** ស្តីពីសកម្មភាពចម្រុះវិស័យកាកបាទក្រហម នៅសាលាខេត្តកំពត មានការចូលរួមពីមន្ត្រីពាក់ព័ន្ធចំនួន **១៧០នាក់**។



*ការធ្វើអង្កេតផ្ទៃក្នុង ស្តីពីការយល់ដឹងក្នុងការប្រើប្រាស់បដិរូប ជូនគណៈកម្មាធិការ ក្រុមប្រតិបត្តិសាខា និងទីប្រឹក្សាយុវជន កក្រក*

- ផ្តល់វគ្គបណ្តុះបណ្តាល និងវគ្គបំប៉ន អំពីគោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ និងវគ្គតម្រង់ទិស អំពីតួនាទីភារកិច្ច ជូនសមាជិក សមាជិកាគណៈកម្មាធិការសាខា និងទីប្រឹក្សាយុវជនកាកបាទក្រហមកម្ពុជាចំនួន **៧០នាក់** នៅខេត្តស្ទឹងត្រែង។



*ពិធីផ្សព្វផ្សាយអំពីគោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ ជូនសិស្ស-និស្សិត និងមន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស*

- ផ្សព្វផ្សាយ អំពីគោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក ជូននិស្សិតសកលវិទ្យាល័យចំនួន ៤ និងគរុសិស្សនៅសាលាគរុកោសល្យ និងវិក្រឹត្យការ ខេត្តស្ទឹងត្រែងចំនួន **៥៦៦នាក់**។

*សកម្មភាពទី៣ ៖ ការងារស្តារទំនាក់ទំនងគ្រួសារ និងបញ្ជូនសារ*

- ទទួលពាក្យសុំស្រាវជ្រាវក្នុងប្រទេសចំនួន **១១ករណី** និងការស្រាវជ្រាវផ្សាយតាមទូរទស្សន៍ ដំណឹងរកគ្រួសារចំនួន ២០ករណី។
- ប្រមូល និងបញ្ជូនលិខិតឆ្លើយឆ្លងចំនួន **៤,៧០៤ច្បាប់** (ពីក្រុមគ្រួសារទៅអ្នកជាប់ឃុំចំនួន ១៦៥ច្បាប់ និងពីអ្នកជាប់ឃុំមកក្រុមគ្រួសារ ៣០,៥៥១ច្បាប់)។
- លិខិតឆ្លើយឆ្លងមិនបានចែកចំនួន **៤៨ច្បាប់** ដោយលិខិតខ្លះមានអាស័យដ្ឋានមិនច្បាស់លាស់ និងខ្លះបដិសេធមិនព្រមទទួល និងពុំទទួលបានការឆ្លើយតបមកវិញចំនួន ៦៣១ច្បាប់។ បានទទួលសារលិខិតឆ្លើយឆ្លងពីអ្នកជាប់ឃុំនៅប្រទេសថៃ ផ្ញើទៅក្រុមគ្រួសារចំនួន **៤១ច្បាប់** ក្នុងនោះបានឆ្លើយតប ២៥ច្បាប់ មិនឆ្លើយតប ៩ច្បាប់ និង៧ច្បាប់មិនបានចែកចាយដោយព័ត៌មានមិនច្បាស់លាស់។



*មន្ត្រីកំពុងចែកសំបុត្រដំណឹងគ្រួសារ និងបងប្អូន ដល់អ្នកជាប់ពន្ធនាគារ និងអ្នកស្វែងរកសមាជិកគ្រួសារដែលបាត់ដំណឹង*

*សកម្មភាពទី៤ ៖ កម្មវិធីសុវត្ថិភាពសហគមន៍*

- ផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពគ្រូបង្គោល អំពីអនាម័យសុខភាព និងការប្រើប្រាស់បង្គន់ ជូនមន្ត្រីទីស្នាក់ការកណ្តាល មន្ត្រីសាខាកាកបាទក្រហមកម្ពុជាខេត្តស្វាយរៀង ក្រចេះ បន្ទាយមានជ័យ និងតំណាងសហព័ន្ធអន្តរជាតិចំនួន **៣៥នាក់**។
- រៀបចំយុទ្ធនាការផ្សព្វផ្សាយ ដើម្បីអបអរសាទរទិវាយល់ដឹង អំពីមីន ២៤កុម្ភៈ នៅតាមសាខាកាកបាទក្រហមកម្ពុជាខេត្តពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ មានអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **២,៥០០នាក់** បានចូលរួម។
- ផ្តល់វគ្គបំប៉ន អំពីមីន ជូនអ្នកស្ម័គ្រចិត្តចំនួន **៩០នាក់** នៅស្រុកវាលវែង និងស្រុកក្រវាញ ខេត្តពោធិ៍សាត់ ស្រុកជាំក្សាន្ត និងស្រុករវៀង ខេត្តព្រះវិហារ។
- ផ្តល់វគ្គអប់រំផ្សព្វផ្សាយចំនួន **១៥០វគ្គ** ដើម្បីលើកកម្ពស់សុវត្ថិភាពសហគមន៍ ជូនកម្មករអ្នកនេសាទ អ្នកប្រមាញ់ អ្នកផ្លាស់ប្តូរទីលំនៅ អ្នករកឈើ អតីតទាហាន អ្នករកដែកលក់ អ្នកប្រកបរបរម៉ូតូឌុប អ្នកបើកបររថយន្តឈ្នួល កុមារក្រៅ និងក្នុងសាលាចំនួន **១១,១២២នាក់** ក្នុងខេត្តពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និងព្រះវិហារ។



អ្នកស្ម័គ្រចិត្តកំពុងពន្យល់ពីគ្រោះថ្នាក់នៃគ្រាប់មីន ឬគ្រាប់មិនទាន់ផ្ទុះ និងបង្ហាញការអនុវត្តមេរៀនវិជ្ជាសង្គ្រោះបឋម

## សកម្មភាពទី៩ ៖ ការផ្តល់ជំនួយសុខុមាលភាពសង្គម

កាកបាទក្រហមកម្ពុជា បានផ្តល់សេវាសង្គម ដើម្បីជួយសម្រាលការលំបាក នៃជនរងគ្រោះដោយការរើសអើង អំពើហិង្សា ពិការភាព ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍។ល។ លទ្ធផលសម្រេចបានដូចខាងក្រោម ៖

- អំណោយកាកបាទក្រហមកម្ពុជាថ្នាក់កណ្តាលក្រោមការដឹកនាំ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** បានផ្តល់ផ្ទះចំនួន **១៣ខ្នង** (ប៉ៃលិន៨ខ្នង កំពត១ខ្នង កំពង់ឆ្នាំង១ខ្នង ព្រះវិហារ១ខ្នង កំពង់ស្ពឺ១ខ្នង និងឧត្តរមានជ័យ១ខ្នង) និងផ្តល់បន្ថែមគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយ ជូនទុរគតជន។



លោកជំទាវអគ្គលេខាធិការរងទី១ ប្រគល់ផ្ទះជូនគ្រួសារពិការនៅខេត្តកំពង់ឆ្នាំង និងគ្រឿងឧបភោគ បរិភោគមួយចំនួនជូនលោកយាយអាយុ៩១ឆ្នាំនៅខេត្តកំពត

- សាខាកាកបាទក្រហមកម្ពុជារាជធានី ខេត្តចំនួន ១៧ បានផ្តល់ផ្ទះចំនួន **១៤៤ខ្នង** ជូនប្រជាពលរដ្ឋក្រីក្រ (កំពង់ចាម៥៧ខ្នង កំពត២៦ខ្នង ប៉ៃលិន២២ខ្នង ព្រៃវែង១១ខ្នង កំពង់ស្ពឺ១០ខ្នង សៀមរាប៣ខ្នង កំពង់ឆ្នាំង៣ខ្នង ព្រះវិហារ៣ខ្នង កណ្តាល១ខ្នង តាកែវ១ខ្នង កែប១ខ្នង ឧត្តរមានជ័យ១ខ្នង បន្ទាយមានជ័យ១ខ្នង បាត់ដំបង១ខ្នង ព្រះសីហនុ១ខ្នង ពោធិ៍សាត់១ខ្នង និងរាជធានីភ្នំពេញ១ខ្នង)។



ឯ.ឧ នាយក នាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ តំណាងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន កក្រក ប្រគល់អណ្តូងស្នប់អាហ្វ្រិដេស៍ ជូនសហគមន៍ និង ផ្ទះ ជូនគ្រួសារក្រីក្រនៅខេត្តព្រះវិហារ

- អំណោយកាកបាទក្រហមកម្ពុជាថ្នាក់កណ្តាលក្រោមការដឹកនាំ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ជាគ្រឿងឧបភោគ បរិភោគ រួមមាន៖ អង្ករ មី មុង ភួយ ឃីត និងថវិកា ៥ម៉ឺនរៀល ក្នុងមួយគ្រួសារ ជូនគ្រួសារយោធិនពិការចំនួន **៤២០គ្រួសារ** រស់នៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ តេជោភ្នំឆ័ត្រ នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។
- ចុះសួរសុខទុក្ខ និងផ្តល់អំណោយ ជូនក្រុមគ្រួសារមន្ត្រីកាកបាទក្រហមកម្ពុជាថ្នាក់ដឹកនាំមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិល្បករ និងប្រជាពលរដ្ឋ ទទួលមរណភាព ដោយរោគាពាធ និងគ្រោះថ្នាក់ផ្សេងៗ និងអ្នកមានជីវភាពក្រីក្រ ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានាចំនួន **៧០នាក់**។





*លោកជំទាវអគ្គលេខាធិការរងទី១ ចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ ជូនគ្រួសារយោធិនពិការ*

- បានសំណេះសំណាលសួរសុខទុក្ខ និងផ្តល់គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ជូននិវត្តជនកាកបាទក្រហមកម្ពុជា **៧២នាក់** ក្នុងទិវាមនុស្សចាស់អន្តរជាតិលើកទី១៨។
- ប្រគល់ខ្នើយ ជូនសមាគមតន្ត្រីសំនៀងជនពិការចំនួន **៥០ខ្នើយ** អង្គការសង្គ្រោះជនអស់សង្ឃឹមចំនួន **៣០០ខ្នើយ** សមាគមរស្មីកុមារកម្ពុជាចំនួន **១០០ខ្នើយ** និងសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រាក្រីក្រចំនួន **៥០ខ្នើយ**។
- បានជួបសំណេះសំណាល ផ្តល់គ្រឿងឧបភោគ បរិភោគ និងថវិកា ជូនសមាគមតន្ត្រីសំនៀងជនពិការចំនួន **៥២នាក់**។





*លោកជំទាវអនុប្រធាន កក្រក ចែកអំណោយមនុស្សធម៌ និងរៀបចំអាហារ ជូនជនងាយរងគ្រោះ នៅអង្គការសង្គ្រោះជនអស់សង្ឃឹម*

## វិស័យស្នូលទី៤ ៖ ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន

ការងារអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន ជាគ្រឹះជួយឲ្យសមាគមជាតិ បានបំពេញការងារក្នុងវិស័យស្នូលទាំង៣ ខាងលើទទួលបានជោគជ័យ និងជំរុញឲ្យស្ថាប័នមនុស្សធម៌ឈានមុខគេនេះក្លាយជា"**សមាគមជាតិមានដំណើរការល្អ**" តាមរយៈការកសាងសមត្ថភាព និងអនុវត្តតាមទិសវិមជ្ឈការ វិសហមជ្ឈការ សំដៅពង្រឹង និងពង្រីករចនាសម្ព័ន្ធ បណ្តាញ ព្រមទាំងលើកកម្ពស់ភាពជាម្ចាស់ របស់សមាគមជាតិពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន។ វិស័យស្នូលទី៤ មានសកម្មភាពចំនួន ៧ សម្រេចលទ្ធផលបានដូចខាងក្រោម ៖

### *សកម្មភាពទី១ ៖ ការអភិបាល និងការគ្រប់គ្រង*

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** សម្តេចអនុប្រធានអចិន្ត្រៃយ៍ លោកជំទាវអនុប្រធានទាំង៣ លោកជំទាវអគ្គហេរញ្ញិក ឯកឧត្តម លោកជំទាវសមាជិក សមាជិកាគណៈកម្មាធិការកណ្តាល គណៈកម្មាធិការសាខា បានបំពេញតួនាទី ភារកិច្ចស្របតាមលក្ខន្តិកៈ សេចក្តីសម្រេច នៃអង្គមហាសន្និបាតអាណត្តិទី៦ សេចក្តីសម្រេច ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ ដោយស្មោះស្ម័គ្រអស់ពីកម្លាំងកាយកម្លាំងចិត្តចូលរួមរៀបចំពិធីធំៗ ឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព បានបន្តពង្រឹងអភិបាលកិច្ចល្អ ការគ្រប់គ្រងមានតម្លាភាព និងគណនេយ្យភាព តាមរយៈការលើកកម្ពស់ស្មារតីទទួលខុសត្រូវរបស់ក្រុមប្រតិបត្តិថ្នាក់កណ្តាល និងសាខាកាកបាទក្រហមកម្ពុជា ឱ្យអនុវត្តតាមគោលនយោបាយ និងមានការតម្រង់ទិសជាប្រចាំ។

ជាងនេះទៀត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** បានដឹកនាំគណៈកម្មាធិការកណ្តាលចូលគាល់ព្រះប្រធានកិត្តិយស **សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ទូលថ្វាយនូវរបាយការណ៍ទៀងទាត់ អំពីវឌ្ឍនភាពរបស់កាកបាទក្រហមកម្ពុជា។ ទន្ទឹមនឹងនេះ ក៏បានថ្វាយកញ្ចប់របាយការណ៍ និងឯកសារថ្វាយ **ព្រះករុណាព្រះមហាក្សត្រ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ផងដែរ។



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន ដឹកនាំកិច្ចប្រជុំប្រចាំឆ្នាំ សមាជិក សមាជិកា គណៈកម្មាធិការកណ្តាល និងក្រុមប្រតិបត្តិ កក្រក*

## *សកម្មភាពទី២ ៖ ការអភិវឌ្ឍន៍សាខា អនុសាខា*

- ឆ្នាំ២០១៦នេះ សាខានីមួយៗ បានខិតខំលើកកម្ពស់អភិបាលកិច្ចល្អដោយពង្រឹងការកៀគរមូលនិធិកសាង និងពង្រឹងរចនាសម្ព័ន្ធពីថ្នាក់សាខា អនុសាខា ក្រុមបណ្ដាញយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា តាមរយៈការតម្រង់ទិសការងារ សម្រាប់អាណត្តិទី៦ និងការងារខាងក្រោម៖
  - ✓ សាខាចំនួន **៥** (សាខា កក្រក ខេត្តក្រចេះ ស្វាយរៀង កំពង់ធំ កំពង់ឆ្នាំង និងកោះកុង) មានការពិនិត្យវឌ្ឍនភាពសាខា ក្រោយពីបានអនុវត្តការប៉ាន់ប្រមាណសមត្ថភាពសាខា។
  - ✓ សាខាចំនួន **៥** (សាខា កក្រក ខេត្តបន្ទាយមានជ័យ ក្រចេះ ត្បូងឃ្មុំ កំពង់ធំ និងកំពង់ឆ្នាំង) បានកសាង និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍សាខា ឆ្នាំ២០១៤-២០១៩ ដែល ឆ្លើយតបនឹងតម្រូវការជាក់ស្ដែងរបស់សហគមន៍។
  - ✓ សាខាចំនួន **២** (សាខា កក្រក ខេត្តព្រៃវែង និងកំពត) បានប្រារព្ធសន្និបាតវិសាមញ្ញ ដើម្បីជ្រើសតាំងគណៈកម្មាធិការសាខាដែលមានថាមភាព។
  - ✓ សាខាចំនួន **៥** (សាខា កក្រក ខេត្តស្ទឹងត្រែង កែប តាកែវ បាត់ដំបង និងប៉ៃលិន) បានអនុវត្តការប៉ាន់ប្រមាណសមត្ថភាពសាខា។
- ដោយមានកំណើនមូលនិធិផ្ទាល់របស់សាខា និងដោយមានបណ្ដាញពីថ្នាក់កណ្ដាល ដល់មូលដ្ឋានពីមួយឆ្នាំទៅមួយឆ្នាំសាខាមានលទ្ធភាពឆ្លើយតបគ្រោះមហន្តរាយ បានទាន់ពេលវេលា បានច្រើនជាងមុនហើយចំមុខសញ្ញា និងធ្វើសកម្មភាពអន្តរវិស័យដូចភ្លៀងរលឹម។




*ឯ.ឧ អគ្គលេខាធិការរងទី២ ដឹកនាំកិច្ចប្រជុំការប៉ាន់ប្រមាណសម្ថភាពសាខា កក្រក ខេត្តបាត់ដំបង និងមន្ត្រីផែនការសម្របសម្រួលការធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍសាខា កក្រក ខេត្តកំពង់ឆ្នាំង*



*គណៈកម្មាធិការសាខា រួមជាមួយមន្ត្រីប្រតិបត្តិ និងយុវជន កក្រក កំពុងចូលរួមប្រជុំពិភាក្សាការប៉ាន់ប្រមាណសមត្ថភាពសាខា កក្រក ខេត្តប៉ៃលិន ដោយមានការសម្របសម្រួលពីមន្ត្រីថ្នាក់កណ្ដាល*

- សាខាបានខិតខំកសាងអគារ ឬទីស្នាក់ការអនុសាខា ដោយទ្បែកបានចំនួន **១១១** លើចំនួនស្រុកសរុប **១៩៧** ក្នុងនោះមានអគារចំនួន ៩៣ ជាកម្មសិទ្ធផ្ទាល់របស់កាកបាទក្រហមកម្ពុជា និង ៨ទៀត ជាទីស្នាក់ការនៅក្នុងរដ្ឋបាលស្រុក។ ជាមួយគ្នានេះ អនុសាខាមួយចំនួន បានរ៉ាប់រងកាឆ្លើយតបគ្រោះមហន្តរាយបានទាន់ពេលវេលាដោយថវិការបស់អនុសាខាផ្ទាល់ (អនុសាខាខ្លះបានរៀបចំទិវា ៨ឧសភា ថ្នាក់អនុសាខា)។
- បានរៀបចំ និងធ្វើបច្ចុប្បន្នកម្ម "សេចក្ដីសម្រេច ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខា" ទូទាំង ២៥ រាជធានី ខេត្ត។

- បានរៀបចំគណៈកិត្តិយស ជ្រើសតាំងគណៈកម្មាធិការ ជ្រើសរើសក្រុមប្រតិបត្តិសាខា អនុសាខា និងក្រុមកាកបាទក្រហមទូទាំងខេត្ត ដែលមានលទ្ធភាព សមត្ថភាពស័ក្តិសមនឹងការរីកចម្រើនរបស់សាខា។
- ពង្រឹង និងពង្រីកបណ្តាញយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា។

## *សកម្មភាពទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស*

### ៣.១. ការងារបុគ្គលិក

- បច្ចុប្បន្នកាកបាទក្រហមកម្ពុជា មានមន្ត្រីប្រតិបត្តិនៅថ្នាក់កណ្តាលចំនួន **១២៤នាក់** មន្ត្រីស្នូល **៩៥នាក់** ទទួលបៀវត្សកាកបាទក្រហមកម្ពុជា និង **២៩នាក់** ផ្សេងទៀតទទួលបៀវត្សពីដៃគូ។
- មានគណៈកិត្តិយសចំនួន **៤២០នាក់** គណៈកម្មាធិការសាខាចំនួន **៣២៤នាក់** មានអនុសាខាចំនួន ១៩៤ មានគណៈកិត្តិយសអនុសាខាចំនួន **១,១៣២នាក់** គណៈកម្មាធិការអនុសាខាចំនួន **១,៤៧០នាក់** និងមន្ត្រីក្រុមប្រតិបត្តិសាខាចំនួន **២៧៣នាក់**។
- សម្របសម្រួលកិច្ចប្រជុំស្វែងរកលទ្ធភាព ជូនមន្ត្រីសាខាកាកបាទក្រហមកម្ពុជាខេត្តកំពង់ធំ និងត្បូងឃ្មុំ ដើម្បីបញ្ចូលក្របខ័ណ្ឌរដ្ឋ។
- ធ្វើបច្ចុប្បន្នកម្មលក្ខខណ្ឌការងារ របស់កាកបាទក្រហមកម្ពុជា។

### ៣.២. ការងារយុវជន និង អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា

យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ពិតជាប្រតិបត្តិករ និងជាកម្លាំងចលករ បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តវិស័យស្នូលទាំង ៤។ លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៦ នេះ មានដូចតទៅ៖

- យុវជនកាកបាទក្រហមកម្ពុជាសរុបចំនួន **២១,៧១០នាក់** (ស្រី១៣,១៧៣នាក់) ទីប្រឹក្សាយុវជនកាកបាទក្រហមកម្ពុជាចំនួន **១,០៥៨នាក់** (ស្រី២៥១នាក់)។ នៅគ្រឹះស្ថានសិក្សាចំនួន **៤៥៦** ទូទាំង ២៣ រាជធានី-ខេត្ត (ប៉ៃលិន និងបន្ទាយមានជ័យ មិនបានផ្តល់សាលាកប័ត្រព័ត៌មាន)។
- អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាទាំង ២៣ រាជធានីខេត្ត មានចំនួនសរុប **១២,១៥៩នាក់** (ស្រី៤,៨៣០នាក់) ដែលបានទទួលការបណ្តុះបណ្តាលជំនាញជាក់លាក់ និងជាប្រតិបត្តិកររបស់គម្រោងកម្មវិធីនីមួយៗ។



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន ផ្តល់កាពស្និទ្ធស្នាលជាមួយយុវជន កក្រក និង សកម្មភាពយុវជនកំពុងចូលរួមដាំកូនឈើនៅខេត្តកំពត*




*យុវជន កក្រក កំពុងទទួលការបណ្តុះបណ្តាលស្តីពី កម្មវិធីយុវជនកាកបាទក្រហមកម្ពុជា*

- កិច្ចប្រជុំយុវជនកាកបាទក្រហមកម្ពុជាថ្នាក់ជាតិ បានប្រារព្ធក្រោមអធិបតីភាព **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន** ជាការលើកទឹកចិត្តជំរុញកម្លាំងយុវជន ឱ្យធ្វើសកម្មភាពចម្រុះវិស័យ ក្នុងនាមជាភ្នាក់ងារ នៃការផ្លាស់ប្តូរឥរិយាបថវិជ្ជមានក្នុងសង្គមតាមរយៈកម្មវិធីមិត្តអប់រំមិត្ត នៅតាមគ្រឹះស្ថានសិក្សា សហគមន៍ និងកន្លែងបំពេញការងារ ដើម្បីបង្ហាញពីទេពកោសល្យ និងគុណតម្លៃជាកូនល្អ ជាមិត្តល្អ សិស្សល្អ និងពលរដ្ឋល្អ សម្រាប់ជាប្រយោជន៍ចំពោះខ្លួនឯង និងសង្គមជាតិទាំងមូល។
- យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **៨,០០២នាក់** ជាប្រតិបត្តិករផ្សព្វផ្សាយ អំពីសុវត្ថិភាពចរាចរណ៍។



*យុវជន កក្រក កំពុងជួយសម្រួលចរាចរណ៍នៅតាមភ្លើងស្តុប និងជួយលាងរបួសទេសចរណ៍បរទេសនៅថ្ងៃបុណ្យសមុទ្រ*

- យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១៣សាខា** បានបញ្ជូនជនរងគ្រោះចំនួន **៣,១៧៧នាក់** ទៅមណ្ឌលសុខភាព។
- យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១២សាខា** បានអប់រំ និងផ្សព្វផ្សាយ អំពីវិជ្ជាសង្គ្រោះបឋម ជូនយុវជន និងអ្នកស្ម័គ្រចិត្ត សិស្សានុសិស្សចំនួន **៨,២៥៤នាក់**។
- សាខាកាកបាទក្រហមកម្ពុជាខេត្តចំនួន ៣ សហការជាមួយគ្រឹះស្ថានឧត្តមសិក្សា ក្រុមហ៊ុនផលិតទឹកបរិសុទ្ធវីតាល់ និងមជ្ឈមណ្ឌលជាតិផ្តល់ឈាម រៀបចំយុទ្ធនាការបរិច្ចាគឈាម ៧លើក ទទួលបានការបរិច្ចាគឈាមដោយស្ម័គ្រចិត្តចំនួន **៤,៣៨៩នាក់**។
- ក្លឹបយុវជនកាកបាទក្រហមកម្ពុជាចំនួន ៤ (នៅភ្នំពេញ១ និងសាខា៣) បានរៀបចំពិធីសប្បុរសធម៌ ទទួលបានថវិកាសរុប **៨៧,០២៧,៦០០រៀល**។
- បានផលិត និង ប្រគល់ប័ណ្ណសម្គាល់ខ្លួន ជូនយុវជនចំនួន **២១,៧១០ប័ណ្ណ** និងអ្នកស្ម័គ្រចិត្តចំនួន **១២,១៥៥ប័ណ្ណ** នៅតាមសាខាកាកបាទក្រហមកម្ពុជារាជធានី-ខេត្ត។
- ផ្តល់អាហារូបករណ៍ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ឆ្នាំ២០១៦ បាន **១០០កន្លែង** ជូនសិស្ស និស្សិត ក្រីក្រ ជាយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន ២៥ រាជធានី ខេត្ត។ ដោយឡែកសាកលវិទ្យាល័យមេគង្គកម្ពុជា ក៏បានផ្តល់អាហារូបករណ៍ ជូនយុវជន និង អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាចំនួន **១០០កន្លែង** សម្រាប់សិក្សានៅរាជធានីភ្នំពេញ។
- ដើម្បីចូលរួមចំណែករំលឹកគុណដល់អ្នកស្ម័គ្រចិត្តពិភពលោក ពិសេសអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ដែលបានចំណាយពេលវេលា ធនធាន ចូលរួមចំណែកជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះនៅ

ក្នុងសហគមន៍ និងគ្រឹះស្ថានសិក្សា មានសាខាចំនួន ១៤ ដោយមានការចូលរួមពីថ្នាក់កណ្តាល បានប្រារព្ធទិវាអន្តរជាតិនៃអ្នកស្ម័គ្រចិត្ត ក្រោមប្រធានបទ៖ **"ស្ម័គ្រចិត្តដើម្បីនិរន្តរភាព"** ដែលមានអ្នកចូលរួមសរុបចំនួន **២,៨៥៣នាក់** និងបានចែកប័ណ្ណសរសើរជូនអ្នកស្ម័គ្រចិត្តចំនួន ២,៥៣២ប័ណ្ណ។ ការប្រារព្ធពិធីនាពេលនេះ គឺសមនឹងទិសស្លោកដែលលើកឡើងថា អ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហមកម្ពុជា គឺជាឆ្អឹងខ្នងរបស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហមអន្តរជាតិ។



*លោកជំទាវអគ្គលេខាធិការរងទី១ កក្រក មានប្រសាសន៍សំណេះសំណាលជាមួយអ្នកចូលរួម និងអ្នកស្ម័គ្រចិត្តឡើងប្តេជ្ញាចិត្ត*

## *សកម្មភាពទី៤ ៖ ការអភិវឌ្ឍនធនធានហិរញ្ញវត្ថុ*

- **ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** បានបរិច្ចាគព្រះរាជទ្រព្យជារៀងរាល់ខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ គាំទ្រយ៉ាងកក់ក្តៅចំពោះសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា។ ដោយឡែក ការប្រារព្ធទិវា ៨ឧសភា ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានការចូលរួមពីភ្ញៀវជាតិអន្តរជាតិ និងសប្បុរសជនយ៉ាងច្រើន ដែលធ្វើឲ្យចំណូលទទួលបាន មានការកើនឡើងគួរជាទីកត់សម្គាល់។ ក្រៅពីសប្បុរសជន ដែលបានបរិច្ចាគក្នុងទិវា ៨ឧសភា កាកបាទក្រហមកម្ពុជាបានទទួលចំណូលពីសប្បុរសជនតាមរយៈ កម្មវិធីចូលជួបសំដែងការគួរសម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធាន** និងថ្នាក់ដឹកនាំកាកបាទក្រហមកម្ពុជា ជាហូរហែដែរ។

## *សកម្មភាពទី៥ ៖ ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ*

- មានដៃគូសហប្រតិបត្តិការសរុបចំនួន ១២ និងបានចងក្រងគោលនយោបាយទំនាក់ទំនង។
- បានចូលរួមបុណ្យខួបអនុស្សាវរីយ៍ទី៧០ របស់កាកបាទក្រហមវៀតណាម។ ឧបត្ថម្ភថវិកា ជូនកាកបាទក្រហមវៀតណាមចំនួន **៥,០០០ដុល្លារ** និងបានពិគ្រោះ អំពីបច្ចុប្បន្នកម្មកិច្ចព្រមព្រៀងសហប្រតិបត្តិរវាងកម្ពុជា វៀតណាម និងឡាវ។
- បានធ្វើជាម្ចាស់ផ្ទះវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីការកសាងសហគមន៍ឈានទៅរកភាពធន់។

- ចូលរួមកិច្ចប្រជុំក្រុមការងារអនុវត្តយុទ្ធសាស្ត្រស្តារទំនាក់ទំនងគ្រួសារ (២០០៨-២០១៨) របស់ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំថ្នាក់ដឹកនាំ កាកបាទក្រហម អឌ្ឍចន្ទក្រហម អាស៊ីអាគ្នេយ៍នៅប្រទេសឥណ្ឌូនេស៊ី។
- ចូលរួមកិច្ចប្រជុំ ស្តីពីយុទ្ធសាស្ត្រស្តារទំនាក់ទំនងគ្រួសារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនៅប្រទេសម៉ាឡេស៊ី។
- ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការបំពេញការងារប្រកបដោយសុវត្ថិភាព នៅប្រទេសសិរីលង្កា។

### *សកម្មភាពទី៦ ៖ ការអភិវឌ្ឍការងាររដ្ឋបាល ហិរញ្ញកិច្ច*

- បានបន្តបញ្ជ្រាបស្មារតីគោរពទម្រង់ការហិរញ្ញវត្ថុកាកបាទក្រហមកម្ពុជា នៅក្នុងចំណោមមន្ត្រីប្រតិបត្តិជាពិសេសនៅថ្នាក់កណ្តាលតាមរយៈកិច្ចប្រជុំនានា ក៏ដូចតាមរយៈការងារប្រចាំថ្ងៃ ដោយបានផ្តោតដោយឡែកលើការចំណាយ ត្រូវមានការទូទាត់ជាវិក្កយបត្រ-សក្ខីបត្រសមស្រប។
- បានធ្វើសវនកម្មលើគណនីសរុប របស់កាកបាទក្រហមកម្ពុជាប្រចាំឆ្នាំ២០១៥។
- បានចូលរួមពិភាក្សាជាមួយក្រុមការងារអភិវឌ្ឍស្ថាប័ន កែសម្រួលលក្ខខណ្ឌការងារកាកបាទក្រហមកម្ពុជា។

### *សកម្មភាពទី៧ ៖ ការកសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍*

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ លើរបាយការណ៍អំពី "**ការពិនិត្យឡើងវិញការអនុវត្តពាក់កណ្តាលទីយុទ្ធសាស្ត្រកាកបាទក្រហមកម្ពុជា ២០១១-២០២០**" ដែលផ្តល់ដោយសហព័ន្ធអន្តរជាតិ ដើម្បីបំពេញបន្ថែមអនុសាសន៍ ចំណុចខ្វះចន្លោះ ដែលបានរកឃើញនៅក្នុងរបាយការណ៍នេះ។
- រៀបចំបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ (២០១៤-២០១៩) របស់សាខាកាកបាទក្រហមកម្ពុជាខេត្តបន្ទាយមានជ័យ ក្រចេះ ត្បូងឃ្មុំ កំពង់ធំ និងកំពង់ឆ្នាំង ដោយមានគណៈកម្មាធិការសាខា អនុសាខា មន្ត្រីប្រតិបត្តិសាខា អនុសាខាទីប្រឹក្សាយុវជន យុវជន និងអ្នកស្ម័គ្រចិត្តចូលរួម។
- ចងក្រង បូកសរុបរបាយការណ៍ពីគ្រប់នាយកដ្ឋាន គម្រោង កម្មវិធី និងពីសាខាប្រចាំឆ្នាំ២០១៥ ដើម្បីបោះពុម្ពចែកផ្សព្វផ្សាយ និងរៀបចំបូកសរុប ពិនិត្យ កែសម្រួលរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់កាកបាទក្រហមកម្ពុជាទាំងថ្នាក់កណ្តាល និងសាខា ក្នុងឆ្នាំ២០១៦ ជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច និងជ្រាបជាសេចក្តីរាយការណ៍។

## ផ្នែកទី២ ៖ ផែនការសកម្មភាពការងារ ឆ្នាំ ២០១៧

### វិស័យស្នូលទី១ - ការគ្រប់គ្រងគ្រោះមហន្តរាយ

- បន្តពិនិត្យកែសម្រួលយុទ្ធសាស្ត្រ គោលការណ៍ណែនាំ បទដ្ឋានប្រតិបត្តិការ និងយន្តការបណ្តុះបណ្តាល ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។
- រួមចំណែកអនុវត្តការងារកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ (ក្របខណ្ឌការងារទីក្រុងសាន់ដាយ ឆ្នាំ២០១៥-ឆ្នាំ២០៣០)។
- បន្តបណ្តុះបណ្តាលបង្កើនសមត្ថភាព ជូនមន្ត្រី យុវជន អ្នកស្ម័គ្រចិត្ត ការអប់រំផ្សព្វផ្សាយ អំពីច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ រៀបចំទិវាលើកកម្ពស់ការយល់ដឹង នៃការកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ បញ្ហាសុខភាព ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។
- បន្តពង្រឹងការគ្រប់គ្រងទិន្នន័យឆ្លើយតបគ្រោះមហន្តរាយតាមសាខា ២៥ រាជធានី ខេត្ត (កែសម្រួល និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យចែកចាយ)។
- បន្តពង្រឹង និងពង្រីកការងារប្រាក់កម្ចីពុំមានការប្រាក់ គាំទ្រដោយមូលនិធិវិលម៉េត ឲ្យមានប្រសិទ្ធភាព។
- បន្តបណ្តុះបណ្តាលសមត្ថភាព និងពង្រីកការអប់រំផ្សព្វផ្សាយ អំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដោយសហការជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ។

### វិស័យស្នូលទី២ - សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍

- បន្តពង្រឹងការអនុវត្តការងារឥស្សរជនឆ្នើមថ្នាក់ជាតិ អំពីសុខភាពមាតា ទារក កុមារ និងជំងឺអេដស៍។
- បន្តពង្រឹងពង្រីក វិជ្ជាសង្គ្រោះបឋម ជូនយុវជន អ្នកស្ម័គ្រចិត្ត សហគមន៍ និងវិជ្ជាសង្គ្រោះបឋមបង់ថ្លៃ។
- បន្តពង្រឹង ពង្រីកការងារអភិវឌ្ឍន៍សុខភាពសហគមន៍ សាងសង់អណ្តូងទឹក ឬស្រះ បង្គន់អនាម័យ និងការអប់រំសុខភាពតាមរយៈយុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា នៅសាខាទាំង២៥។
- បន្តពង្រឹងសមត្ថភាពសាខាកាកបាទក្រហមកម្ពុជា ក្នុងការអនុវត្តវិស័យស្នូលខាងលើ។
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធទាំងថ្នាក់ជាតិ និងអន្តរជាតិ។

### វិស័យស្នូលទី៣ - លើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌

- ប្រារព្ធទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ខួបទី ១៥៤ ឆ្នាំ២០១៧។
- រៀបចំពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា។
- រៀបចំបណ្តុះបណ្តាល ស្តីពីការកៀរគរកមូលនិធិ និងសមាជិកភាព ជូនសាខាទាំង ២៥ រាជធានី ខេត្ត និងការកសាងគោលនយោបាយ ស្តីពីការងារកៀរគរកមូលនិធិ និងសមាជិកភាព។
- ពង្រឹងគុណភាពការងារស្តារទំនាក់ទំនងគ្រួសារទាំងក្នុង និងក្រៅប្រទេសឲ្យកាន់តែប្រសើរ។
- បន្តសកម្មភាពកម្មវិធីសុវត្ថិភាពសហគមន៍ ជាមួយដៃគូ គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម និងអាជ្ញាធរមីនកម្ពុជា នៅសាខាគោលដៅទាំង៤ តាមរយៈការធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីមីន សុខភាព អនាម័យ សុវត្ថិភាពចរាចរណ៍ ផ្តល់ប្រាក់កម្ចីពុំមានការប្រាក់ និងស្តារស្រះទឹក។

- លើកកម្ពស់ការអនុវត្តការងារប្រកបដោយសុវត្ថិភាព តាមរយៈបន្តការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹង អំពីគោលការណ៍គ្រឹះរបស់ចលនា ច្បាប់មនុស្សធម៌អន្តរជាតិ ការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម អឌ្ឍចន្ទក្រហមទាំងក្នុង និងក្រៅកាកបាទក្រហមកម្ពុជា។
- រៀបចំវេទិកាយុវជនតាមរយៈទូរទស្សន៍ ដោយមានការចូលរួមពីនិស្សិតសាកលវិទ្យាល័យចំនួន៤ នៅរាជធានីភ្នំពេញ និងទិវាប្រឡងគំនូរកុមារមកពី២៥ រាជធានី ខេត្ត បង្ហាញពីសកម្មភាពចម្រុះវិស័យទាំង៤ របស់កាកបាទក្រហមកម្ពុជា។

## វិស័យស្នូលទី៤ - ការអភិវឌ្ឍស្ថាប័ន និងការអភិវឌ្ឍធនធាន

### សកម្មភាពទី១. ការអភិបាល និងការគ្រប់គ្រង

១. ចុះអភិបាលកិច្ចសាខាកាកបាទក្រហមកម្ពុជាចំនួន ៦ ដើម្បីពង្រឹងការអនុវត្តសេចក្តីសម្រេចចិត្តមហាសន្និបាតអាណត្តិទី៦ កម្រងច្បាប់ និងគោលការណ៍ណែនាំនានា ដើម្បីការងារអភិបាល និងគ្រប់គ្រងកាន់តែប្រសើរឡើងជាងមុន។

២. រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ជូនគណៈកម្មាធិការកណ្តាល និងគណៈកម្មាធិការសាខា។

៣. រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ បូកសរុបលទ្ធផលការងារកក្រេក ទូទាំងប្រទេសជាមួយថ្នាក់ដឹកនាំសាខាទាំង២៥ រាជធានី-ខេត្ត។

៤. រៀបចំកិច្ចប្រជុំវាយតម្លៃការអនុវត្តការងារអភិវឌ្ឍស្ថាប័ន (រួមបញ្ចូលការប៉ាន់ប្រមាណសមត្ថភាពសាខាវិមជ្ឈការ វិសហមជ្ឈការ)។

៥. ជំរុញឲ្យមានកិច្ចប្រជុំប្រចាំឆ្នាំបូកសរុបសកម្មភាពយុវជនតាមសាខានីមួយៗ និងថ្នាក់ជាតិ ព្រមទាំងចុះជួយបណ្តុះបណ្តាលយុវជនកាកបាទក្រហមកម្ពុជា (វគ្គបណ្តុះបណ្តាលគ្រូបង្គោល) នៅតាមសាខាគោលដៅចំនួន ៦។

៦. សិក្សាស្វែងយល់ឯកសារ ដើម្បីត្រៀមលក្ខណៈធ្វើការប៉ាន់ប្រមាណសមត្ថភាពស្ថាប័ន។

៧. ផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីការលើកទឹកចិត្តក្នុងភាពជាអ្នកដឹកនាំ ជូនមន្ត្រីថ្នាក់កណ្តាល និងសាខាដើម្បីបង្កើនគុណភាពក្នុងការបំពេញការងារប្រចាំថ្ងៃកាន់តែប្រសើរឡើង។

៨. រៀបចំការជួបជុំ សំណេះសំណាលជាមួយមន្ត្រីចូលនិវត្តន៍ ឲ្យបានយ៉ាងតិច១ដង ឬ ២ដង រៀងរាល់ឆ្នាំ។

### សកម្មភាពទី២. ការងារអភិវឌ្ឍសាខា អនុសាខា

១. រៀបចំនីតិវិធី សម្រាប់សន្និបាតអនុសាខាកាកបាទក្រហមកម្ពុជា អាណត្តិទី១។

២. ផ្តល់វគ្គបំប៉នសមត្ថភាព ជូនសាខា អនុសាខាមួយចំនួន អំពីដំណើរការគ្រប់គ្រងតាមទិសវិមជ្ឈការ វិសហមជ្ឈការ និងដំណើរការប្រព្រឹត្តទៅរបស់សាខា តាមលក្ខណៈវិនិច្ឆ័យសាខាមានដំណើរការល្អ។

៣. ធ្វើបច្ចុប្បន្នកម្មវិធីសាស្ត្រក្នុងការពិនិត្យឡើងវិញការប៉ាន់ប្រមាណសមត្ថភាពសាខា និងពិនិត្យវឌ្ឍនភាពសាខាក្រោយពីបានអនុវត្តការប៉ាន់ប្រមាណសមត្ថភាពសាខារួច។

៤. រៀបចំឲ្យមានកញ្ចប់ការងារអប្បបរមាសម្រាប់សាខា និងការជំរុញឱ្យមានអគារទីស្នាក់ការអនុសាខាបានគ្រប់ស្រុកទូទាំងខេត្តនីមួយៗ។

### *សកម្មភាពទី៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស*

១. ជំរុញសាខាក្នុងការពង្រឹងការងារអនុវត្តតួនាទីទៅតាមតារាងបរិយាយការងាររបស់បុគ្គលិកម្នាក់ៗ។
២. ជំរុញឱ្យមានការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំបូកសរុបសកម្មភាពយុវជនតាមសាខានីមួយៗ និងថ្នាក់ជាតិ។
៣. ផ្តល់វគ្គបណ្តុះបណ្តាលមូលដ្ឋាន ជូនប្រធានក្លឹបយុវជននៅតាមសាខាគោលដៅចំនួន ៥ (ខេត្ត តាកែវ បន្ទាយមានជ័យ ត្បូងឃ្មុំ បាត់ដំបង កំពង់ចាម)។
៤. ផ្តល់វគ្គបណ្តុះបណ្តាលមូលដ្ឋាន និងវគ្គបំប៉ន ជូនទីប្រឹក្សាយុវជន យុវជន និងអ្នកស្ម័គ្រចិត្ត។

### *សកម្មភាពទី៤. ការអភិវឌ្ឍធនធានហិរញ្ញវត្ថុ*

កសាងគោលនយោបាយ ឬគោលការណ៍ណែនាំ ស្តីពីការអភិវឌ្ឍធនធានហិរញ្ញវត្ថុ។

### *សកម្មភាពទី៥. ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ*

កសាងគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ។

### *សកម្មភាពទី៦. ការអភិវឌ្ឍការងាររដ្ឋបាល ហិរញ្ញកិច្ច*

១. ផ្តល់វគ្គបណ្តុះបណ្តាល និងវគ្គបំប៉ន អំពីការងាររដ្ឋបាល គោលនយោបាយ និងទម្រង់ការហិរញ្ញវត្ថុ ជូនមន្ត្រីពាក់ព័ន្ធថ្នាក់កណ្តាល និងសាខា។
២. រៀបចំកម្មវិធីគណនេយ្យកុំព្យូទ័រ "QuickBooks Enterprise" ដាក់ជូនសាខាចំនួន ៣-៤ (តាមការជ្រើសរើស) ដើម្បីប្រើប្រាស់ក្នុងកម្រិតជាគម្រោងសាកល្បង ហើយប្រមើលមើលលទ្ធភាព នៃការពង្រីកគម្រោងនេះដល់សាខាឯទៀតជាជំហានៗ។
៣. ជួយសាខាក្នុងការងាររៀបចំត្រៀមសម្រាប់ដំណើរការសវនកម្មផ្ទៃក្នុងរបស់សាខា។

### *សកម្មភាពទី៧. ការកសាងផែនការ ពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍*

១. ពង្រឹងការងារផែនការ ពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍ នៅតាមបណ្តាសាខា ជាវគ្គបណ្តុះបណ្តាល និងបំប៉ន។
២. ពង្រឹងសមត្ថភាពដល់ក្រុមការងារពង្រឹងការងារផែនការ ពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍ នៅថ្នាក់កណ្តាល (តាមនាយកដ្ឋាន)។
៣. បន្តជួយកសាង ឬធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍសាខា (២០១៤-២០១៩) នៃសាខាគោលដៅចំនួន ៨ (ខេត្តកំពង់ចាម កំពត ព្រះវិហារ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងប៉ៃលិន)។

## សេចក្ដីសន្និដ្ឋាន

កត្តាសត្យានុម័ត ដែលនាំឱ្យកាកបាទក្រហមកម្ពុជា សម្រេចបានជោគជ័យដ៏ធំធេង ដូចបានរៀបរាប់ខាងលើ គឺដោយសារវរគំរូដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដែលបានឧបត្ថម្ភគាំទ្រ បំពេញបន្ថែមនូវគុណតម្លៃ នៃឋានៈស្របច្បាប់របស់កាកបាទក្រហមកម្ពុជា ជាជំនួយការឱ្យអាជ្ញាធរសាធារណៈ ក្នុងវិស័យមនុស្សធម៌ ហើយកាយវិការប្រកបដោយសេចក្តីស្មោះស្ម័គ្រនេះ ព្រមទាំងគោលគំនិតដ៏ថ្លៃថ្លារបស់**សម្ដេចតេជោ** ក្នុងការប្រមូលផ្ដុំកម្លាំងសរុប ជួយឧបត្ថម្ភគាំទ្រសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា បានធ្វើឱ្យគណៈកិត្តិយស គណៈកម្មាធិការសាខា គ្រប់ថ្នាក់ខិតខំប្រឹងប្រែង ជាពិសេសការពង្រឹងលើកកម្ពស់ភាពជាម្ចាស់ ទាំងនៅថ្នាក់កណ្តាល ក៏ដូចជាសាខា ដោយឈរលើគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ បានទទួលជោគជ័យគួរជាទីមោទនៈ រួមទាំងកត្តាកំណត់ និងសំខាន់បំផុតនោះ គឺការដឹកនាំប្រកបដោយសុឆន្ទៈ និងភាពជាអ្នកដឹកនាំប្រកបដោយភាពឈ្លាសវៃ និងមានប្រសិទ្ធភាពជាប់ជាប្រចាំរបស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន** ដែលបានលះបង់អស់កម្លាំងកាយចិត្ត និងពេលវេលា យកទុក្ខលំបាករបស់ជនរងគ្រោះ និងងាយរងគ្រោះ ជាអាទិភាព និងបានណែនាំតម្រង់ទិសការងារដោយផ្ទាល់ និងដោយប្រយោល មិនគិតពីការនឿយហត់ជាមួយគណៈកម្មាធិការសាខាទាំង ២៥ រាជធានី ខេត្ត ទើបឆ្នាំនេះមាន វឌ្ឍនភាពទាំងសមត្ថភាព ទាំងធនធាន និងសកម្មភាពរបស់សាខានីមួយៗ បានលើកកម្ពស់គួរឱ្យកត់សម្គាល់ ទោះបីជាសកលលោកជួបបញ្ហាប្រឈមមួយចំនួន ដូចជាការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលសង្គ្រាមនៅតំបន់មជ្ឈឹមបូព៌ាក៏ដោយ ក៏កម្ពុជានៅតែ សម្រេចបានការអភិវឌ្ឍលើគ្រប់វិស័យ ឆ្លងផុតពីប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

សមិទ្ធផល និងជោគជ័យដែលសម្រេចបាននេះ បានផ្តល់នូវភាពកក់ក្តៅចំពោះអ្នកទទួលផល ហើយក៏បានលើកកម្ពស់ជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន ពោលគឺកាកបាទក្រហមកម្ពុជា បានបំពេញបេសកកម្ម ស័ក្តិសមនឹងទិសស្លោកប្រចាំឆ្នាំ "**កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា**" ។

# យុទ្ធសាស្ត្រ ២០១១-២០២០

## ទស្សនវិស័យ បេសកកម្ម ទិសយុទ្ធសាស្ត្រ និង វិស័យស្នូលទាំង ៤

### ទស្សនវិស័យ ២០២០

រួមចំណែក**ពន្លឿន**ការកាត់បន្ថយភាពក្រីក្រ
ការពារសេចក្ដីថ្លៃថ្នូរបស់មនុស្សជាតិ
និងការពារតម្លៃមនុស្សធម៌របស់ជនរងគ្រោះ

### បេសកកម្ម

ជាសមាគមជាតិនាំមុខគេក្នុងវិស័យមនុស្សធម៌ កាកបាទក្រហមកម្ពុជាប្រមូលផ្ដុំកម្លាំងមនុស្សធម៌
ដើម្បីបន្ដជួយដល់ជនរងគ្រោះបំផុត តាមរយៈការគ្រប់គ្រងគ្រោះមហន្ដរាយ
សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍ និងការលើកកម្ពស់គោលការណ៍គ្រឹះ និងតម្លៃមនុស្សធម៌របស់ចលនា

### ទិសយុទ្ធសាស្ត្រទី ១

រួមចំណែកសង្គ្រោះជីវិត
កសាងភាពធន់មាំទៅនឹងគ្រោះមហន្ដរាយ
និងវិបត្តិផ្សេងៗ

**វិស័យស្នូលទី ១**
ការគ្រប់គ្រងគ្រោះមហន្ដរាយ

### ទិសយុទ្ធសាស្ត្រទី ២

រួមចំណែកកាត់បន្ថយ អត្រាឈឺ និងស្លាប់
នៃមាតា ទារក និងកុមារ ការពារជំងឺឆ្លង និង
អន្ដរាគមន៍សុខភាពក្នុងគ្រាអាសន្ន

**វិស័យស្នូលទី ២**
សុខភាព និងការថែទាំសុខភាពក្នុងសហគមន៍

### ទិសយុទ្ធសាស្ត្រទី ២

លើកកម្ពស់គោលការណ៍គ្រឹះ
តម្លៃមនុស្សធម៌ សេចក្ដីថ្លៃថ្នូរ របស់
មនុស្សជាតិ និងវប្បធម៌អហិង្សា

**វិស័យស្នូលទី ៣**
លើកកម្ពស់គោលការណ៍គ្រឹះ និង
តម្លៃមនុស្សធម៌របស់ចលនា

**ទិសយុទ្ធសាស្ត្រទី ៤ :** ធានាពង្រឹងការរក្សាកិត្តិនាម កិត្យានុភាពកាកបាទក្រហមកម្ពុជា ជាសមាគមជាតិនាំមុខគេក្នុងវិស័យមនុស្សធម៌
វិស័យស្នូលទី ៤ : ការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍធនធាន

**បញ្ហាអន្ដរវិស័យ :** សមាជិក-សមាជិកា អ្នកស្ម័គ្រចិត្ត យេនឌ័រ យុវជន ការកសាងសមត្ថភាព និងការស្វែងរកការគាំទ្រ

## ចំណូលថវិកា ឆ្នាំ ២០១៦ វិភាគតាមប្រភព




## ចំណាយថវិកា ឆ្នាំ ២០១៦ វិភាគតាមវិស័យ



# កាកបាទក្រហមកម្ពុជា

## តារាងទិន្នន័យអណ្តូងទឹក ស្រះទឹកនៅតាមសាខាកាកបាទក្រហមកម្ពុជាគោលដៅចំនួន ១២ ឆ្នាំ ២០១៦

| ល.រ | សាខាខេត្ត | អណ្តូងទឹក ស្រះទឹកសហគមន៍ និងផ្ទះសហគមន៍ | | | | | | ទីតាំង និងចំនួនអ្នកទទួលផល | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អណ្តូងស្នប់-លូចំរុះ | ស្រះទឹកសហគមន៍ | ផ្ទះ (ខ្នង) | បង្គន់ | ស៊ីទែនទឹក | ជួសជុលអណ្តូង | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋទទួលផល |
| ១ | ព្រះវិហារ (ស្នប់អាហ្វ្រីដេស) | ១១ | ០ | ០ | ០ | | | ១ | ១ | ៥ | ២៤៨ | ១,២៤០ |
| | ព្រះវិហារ (ស្នប់អាហ្វ្រីដេស) | ១៤ | ០ | ០ | ០ | | | ១ | ១ | ៦ | ៣២៩ | ១,៦៤៥ |
| | ព្រះវិហារ (ស្នប់អាហ្វ្រីដេស) | ១១ | ០ | ០ | ០ | | | ១ | ២ | ៤ | ១៧៩ | ៨៩៥ |
| | ព្រះវិហារ (ស្នប់អាហ្វ្រីដេស) | ១៩ | ០ | ០ | ០ | | | ១ | ១ | ៧ | ២២៨ | ៦៧៨ |
| ២ | បាត់ដំបង | ០ | ៤ | ០ | ០ | | | ៣ | ៤ | ៤ | ៦៧៨ | ៣,៣៩០ |
| ៣ | ឧត្តរមានជ័យ | ០ | ១៣ | ០ | ០ | | | ៥ | ៨ | ១០ | ២,០៩៦ | ១០,៤៨០ |
| ៤ | ស្ទឹងត្រែង (ស្នប់អាហ្វ្រីដេស) | ២០ | ០ | ០ | ០ | | | ១ | ២ | ៥ | ៤៤៩ | ៣,១៤៣ |
| | ស្ទឹងត្រែង (ស្នប់អាហ្វ្រីដេស) | ២០ | ០ | ០ | ០ | | | ៣ | ៧ | ១១ | ៣៧៦ | ២,២១៦ |
| ៥ | តាកែវ | ០ | ១(ផ្លូវ២ខ្សែ) | ០ | ០ | | | ១ | ១ | ១ | ៣១០ | ១,២៩៧ |
| ៦ | ក្រចេះ(ស្នប់អាហ្វ្រីដេស) | ២០ | ០ | ០ | ០ | | | ១ | ២ | ៥ | ១,៣៩៧ | ១៨,២៣៨ |
| ៧ | ពោធិ៍សាត់ (ស្នប់អាហ្វ្រីដេស) | ១៦ | ០ | ០ | ០ | | | ៣ | ៥ | ១៣ | ៣,២៩៣ | ១៤,២៦៩ |
| ៨ | កំពង់ឆ្នាំង | ៣ | ០ | ០ | ០ | ៥ | ២ | ១ | ១ | ១ | ៥សាលា | ២,២៩១ |
| ៩ | កំពត (ស្នប់អាហ្វ្រីដេស) | ១ | ០ | ០ | ០ | | | ១ | ១ | ១ | ២០ | ១០០ |
| ១០ | បន្ទាយមានជ័យ (មណ្ឌលជនពិការភ្នំផ័ត្រ) ស្នប់អាហ្វ្រីដេស | ១៥ | ០ | ០ | ០ | | | ១ | ១ | ១ | ២៧៤ | ៧៧៩ |
| | បន្ទាយមានជ័យ (ខ្នាតមធ្យម) | ៥ | ០ | ០ | ០ | | | ១ | ១ | ១ | ៨៥ | ៤២៥ |
| ១១ | កំពង់ស្ពឺ | ១ | ០ | ០ | ០ | ២ | ០ | ១ | ១ | ១ | ១សាលារៀន | ៤៩២ |
| ១២ | មណ្ឌលគិរី | ១២ | ០ | ០ | ០ | | | ១ | ៣ | ៧ | ២៨៣ | ១,៤១៥ |
| សរុប ៖ | | ១៦៨ | ១៨ | ០ | ០ | ៧ | ២ | ២៧ | ៤២ | ៨៣ | ១០,២៤៥ | ៦២,៩៩៣ |

## កាកបាទក្រហមកម្ពុជា

### តារាងទិន្នន័យសាខាកាកបាទក្រហមកម្ពុជាដែលបានរៀបចំទិវាអន្តរជាតិ នៃអ្នកស្ម័គ្រចិត្ត ឆ្នាំ ២០១៦

| ល.រ | សាខា កក្រក | ថ្ងៃប្រារព្ធទិវា | អ្នកចូលរួមសរុប | ប័ណ្ណសរសើរ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | អត់រៀបចំ | ០ | ០ | |
| ២ | កំពង់ចាម | ២៥ ធ្នូ ២០១៦ | ៣១៥ | ៦៤ | ឯ.ឧ លន់ លឹមថៃ |
| ៣ | កំពង់ស្ពឺ | ២០ ធ្នូ ២០១៦ | ១៥០ | ៥០ | ឯ.ឧ គុង សេង |
| ៤ | ស្វាយរៀង | ៨ ធ្នូ ២០១៦ | ៤២០ | ៤០២ | ល.ជ ម៉ែន នារីសោភ័គ |
| ៥ | ក្រចេះ | អត់រៀបចំ | ០ | ០ | |
| ៦ | ត្បូងឃ្មុំ | ២០ ធ្នូ ២០១៦ | ៣០០ | ១៥០ | ឯ.ឧ លី ឡេង |
| ៧ | កណ្តាល | អត់រៀបចំ | ០ | ៥០០ | |
| ៨ | តាកែវ | អត់រៀបចំ | ០ | ៩ | |
| ៩ | ព្រៃវែង | ៧ ធ្នូ ២០១៦ | ២៩៥ | ៦៥ | ឯ.ឧ សុខ ផេង |
| ១០ | រតនគិរី | អត់រៀបចំ | ០ | ១០០ | |
| ១១ | កំពង់ធំ | ១៤ ធ្នូ ២០១៦ | ៣២០ | ០ | ល.ជ ឃួន ឃុនឌី |
| ១២ | ព្រះសីហនុ | ៥ ធ្នូ ២០១៦ | ៧០ | ០ | ឯ.ឧ យន្ត មីន |
| ១៣ | កំពត | ៥ ធ្នូ ២០១៦ | ២៥៥ | ២៦៥ | ឯ.ឧ ចាន់ ជេស្តា |
| ១៤ | បន្ទាយមានជ័យ | ៥ ធ្នូ ២០១៦ | ២០៥ | ១០៣ | ឯ.ឧ លី សារី |
| ១៥ | បាត់ដំបង | អត់រៀបចំ | ០ | ០ | ឯ.ឧ ប៊ុត គឹមស៊ាន |
| ១៦ | កំពង់ឆ្នាំង | អត់រៀបចំ | ០ | ១៥០ | |
| ១៧ | ប៉ៃលិន | អត់រៀបចំ | ០ | ០ | |
| ១៨ | ពោធិ៍សាត់ | ២៣ ធ្នូ ២០១៦ | ១១៩ | ០ | ឯ.ឧ ខូយ រីដា |
| ១៩ | មណ្ឌលគិរី | ៤ ធ្នូ ២០១៦ | ១១៥ | ០ | នាយកសាខា |
| ២០ | កោះកុង | ២៥ វិច្ឆិកា ២០១៦ | ១៣៦ | ៦២ | ល.ជ ឈួង ឆាលីតប៊ុនលើត |
| ២១ | សៀមរាប | ៥ ធ្នូ ២០១៦ | ១០៧ | ៦២ | ឯ.ឧ សៀង ណាំ |
| ២២ | ស្ទឹងត្រែង | អត់រៀបចំ | ០ | ៥០ | |
| ២៣ | ព្រះវិហារ | អត់រៀបចំ | ០ | ១០៨ | |
| ២៤ | ឧត្តរមានជ័យ | ២៤ ធ្នូ ២០១៦ | ៩៦ | ២៩២ | ឯ.ឧ សរ ថាវី |
| ២៥ | កែប | អត់រៀបចំ | ០ | ១០០ | |
| សាខាបានរៀបចំទិវា ១៤សាខា (អត់ ១១សាខា) | | | ២៩០៣ នាក់ | ២៥៣២ ប័ណ្ណ | |

# កាកបាទក្រហមកម្ពុជា

## តារាងទិន្នន័យអគារអនុសាខាទាំង ២៥ រាជធានី ខេត្ត

| ល.រ | សាខាក្រុង | ចំនួន អនុសាខា | អាគារការិយាល័យអនុសាខា | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ទីតាំងកម្មសិទ្ធ ក្រុង | សាងសង់ក្នុង បរិវេណស្រុក | ស្ថិតនៅ ជាមួយស្រុក | |
| ១ | បន្ទាយមានជ័យ | ៩ | ០ | ០ | ៩ | |
| ២ | បាត់ដំបង | ១៤ | ៩ | ២ | ៣ | |
| ៣ | កំពង់ចាម | ១០ | ២ | ៦ | ២ | |
| ៤ | កំពង់ឆ្នាំង | ៨ | ០ | ៣ | ៥ | |
| ៥ | កណ្ដាល | ១១ | ១ | ១០ | ០ | |
| ៦ | កែប | ២ | ០ | ០ | ២ | |
| ៧ | កោះកុង | ៧ | ២ | ១ | ៤ | |
| ៨ | កំពត | ៨ | ១ | ៤ | ៣ | |
| ៩ | កំពង់ស្ពឺ | ៨ | ១ | ៧ | ០ | |
| ១០ | ក្រចេះ | ៦ | ២ | ៣ | ១ | |
| ១១ | កំពង់ធំ | ៨ | ២ | ៤ | ២ | |
| ១២ | មណ្ឌលគីរី | ៥ | ០ | ០ | ៥ | |
| ១៣ | ឧត្តរមានជ័យ | ៥ | ០ | ១ | ៤ | |
| ១៤ | ប៉ៃលិន | ២ | ១ | ១ | ០ | |
| ១៥ | ភ្នំពេញ | ១២ | ០ | ០ | ១២ | |
| ១៦ | ពោធិ៍សាត់ | ៦ | ៥ | ០ | ១ | |
| ១៧ | ព្រៃវែង | ១៣ | ០ | ១២ | ១ | |
| ១៨ | ព្រះវិហារ | ៨ | ៣ | ០ | ៥ | |
| ១៩ | រតនគិរី | ៩ | ០ | ០ | ៩ | |
| ២០ | ព្រះសីហនុ | ៤ | ០ | ៤ | ០ | |
| ២១ | ស្វាយរៀង | ៨ | ១ | ៧ | ០ | |
| ២២ | សៀមរាប | ១២ | ៤ | ០ | ៨ | |
| ២៣ | ស្ទឹងត្រែង | ៥ | ០ | ០ | ៥ | |
| ២៤ | តាកែវ | ១០ | ០ | ២ | ៨ | |
| ២៥ | ត្បូងឃ្មុំ | ៧ | ០ | ៣ | ៤ | |
| **សរុប** | | **១៩៧** | **៣៤** | **៧០** | **៩៣** | |

# រចនាសម្ព័ន្ធ កាកបាទក្រហមកម្ពុជា ទីស្នាក់ការកណ្តាល






ជ័យលាភីលេខ១ គំនូរកុមារ លើសកម្មភាពចម្រុះវិស័យកាកបាទក្រហមកម្ពុជា ឆ្នាំ២០១៦









# គោលការណ៍គ្រឹះទាំង ៧
## របស់ចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម

### ភាពមនុស្សធម៌

ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម កើតឡើងដោយបំណងប្រាថ្នាសំដៅ ជួយជនរងរបួសនៅក្នុងសមរភូមិ ដោយមិនបែងចែក ឬ រើសអើង ខិតខំខ្នះខ្នែងទៅតាមសមត្ថភាពជាតិ និងអន្តរជាតិរបស់ខ្លួន ដើម្បីបង្ការ និងកាត់បន្ថយទុក្ខលំបាកវេទនា របស់មនុស្សលោកនៅគ្រប់ទីកន្លែងដែលជួបប្រទះ ។ គោលបំណងនៃចលនាគឺការពារជិវិត និង សុខភាព ហើយធានា ការគោរពមនុស្សលោក។ ចលនានឹងលើកកម្ពស់ការយោគយល់គ្នាទៅមវិញ-ទៅមក មិត្តភាពសហប្រតិបត្តិការ និងសន្តិភាពស្ថិតស្ថេរ ក្នុងចំណោមជនគ្រប់រូប ។

### ភាពមិនលំអៀង

ជាភាពមិនបែងចែក ឬ រើសអើងសញ្ជាតិ ពូជសាសន៍ ជំនឿសាសនា វណ្ណៈ ឬទស្សនៈនយោបាយឡើយ។ ភាពមិនលំអៀង ខិតខំប្រឹងប្រែងសម្រាលការឈឺចាប់ខ្លោចផ្សារបស់ជនគ្រប់រូប ដោយចំពោះតែអ្នកដែលត្រូវការចាំបាច់ឱ្យជួយ និងជូនអាទិភាពដល់ករណីដែលជាគ្រោះអាសន្នជាងគេ ។

### អព្យាក្រឹតភាព

ដើម្បីបន្តរក្សាក្តីសោមនស្សរីករាយ និងជំនឿទុកចិត្តពីគ្រប់មជ្ឈដ្ឋាន ចលនាមិនគម្បីចូលរួមក្នុងអារិភាព ឬទោះជាក្នុងកាលៈទេសៈណាក៏ដោយ មិនចូលរួមក្នុងការវែកញែករកខុសត្រូវក្នុងបញ្ហានយោបាយ ពូជសាសន៍ជំនឿសាសនា មនោគមន៍វិជ្ជាឡើយ។

### ឯករាជ្យភាព

ចលនាត្រូវតែឯករាជ្យ។ សមាគមជាតិ ទោះជាជំនួយការឱ្យរដ្ឋាភិបាលខាងសេវាកម្មមនុស្សធម៌ និងស្ថិតនៅក្រោមច្បាប់របស់ប្រទេសជាតិក៏ដោយ ក៏ជានិច្ចកាលត្រូវតែរក្សាស្វ័យភាពរបស់ខ្លួន ដើម្បីអាចធ្វើសកម្មភាពបានស្របតាមគោលការណ៍គ្រឹះនៃចលនា ។

### សេវាកម្មស្ម័គ្រចិត្ត

គឺជាអង្គការសង្គ្រោះដោយស្ម័គ្រចិត្តមួយ ដែលមិនមែនធ្វើសកម្មភាពដោយសារតែចង់បានផលចំណេញនោះឡើយ។

### ឯកភាព

នៅក្នុងប្រទេសមួយ អាចមានសមាគមជាតិតែមួយគត់។ សមាគមជាតិនោះត្រូវតែបើកចំហជូនជនគ្រប់រូប ហើយត្រូវបំពេញភារកិច្ចមនុស្សធម៌នៅទូទាំងប្រទេស។

### សកលភាព

ចលនាកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ក្នុងនោះគ្រប់សមាគមជាតិទាំងអស់ មានឋានៈស្មើគ្នា មានការទទួលខុសត្រូវ និងករណីកិច្ចដូចៗគ្នា ក្នុងការជួយគ្នាទៅវិញ-ទៅមក គឺជាលក្ខណៈសកល។

ឡូត៍ ១៦A ផ្លូវ ៦៥២ កែង ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Lot: 16A, St 652@271, O Bek Kaam, Sangkat Toek Laak 3, Khan Tuol Kork, Phnom Penh, Kingdom of Cambodia
Tel: (855-23) 881 511, Fax: (855-23) 881 522, P.O. Box: 69, Web: www.redcross.org.kh, E-mail: info@redcross.org.kh, crc_adm@online.com.kh